# គោលការណ៍ និងគោលការណ៍ណែនាំ
# អង្គការសហប្រជាជាតិ
# ស្តីពី
# សិទ្ធិទទួលបានជំនួយផ្នែកច្បាប់
# នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

ចែកជូនដោយឥតគិតថ្លៃ

# គោលការណ៍ និងគោលការណ៍ណែនាំ
# អង្គការសហប្រជាជាតិ
# ស្តីពី
# សិទ្ធិទទួលបានជំនួយផ្នែកច្បាប់
# នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

នេះគឺជាបោះពុម្ពផ្សាយដោយ
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ
ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

United Nations
Human Rights

OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS
Cambodia Country Office - Phnom Penh - Cambodia

**ខែវិច្ឆិកា ឆ្នាំ២០១៣**

# មាតិកា

ទំព័រ

ក. សេចក្តីផ្តើម..........................................................................................១៣

ខ. គោលការណ៍.........................................................................................២០

- គោលការណ៍ទី១៖ សិទ្ធិទទួលបានជំនួយផ្នែកច្បាប់...................................២០
- គោលការណ៍ទី២៖ ការទទួលខុសត្រូវរបស់រដ្ឋ.......................................២០
- គោលការណ៍ទី៣៖ ជំនួយផ្នែកច្បាប់សំរាប់ជនដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ.......................................២២
- គោលការណ៍ទី៤៖ ជំនួយផ្នែកច្បាប់សំរាប់ជនរងគ្រោះពីឧក្រិដ្ឋកម្ម............២២
- គោលការណ៍ទី៥៖ ជំនួយផ្នែកច្បាប់សំរាប់សាក្សី...................................២៣
- គោលការណ៍ទី៦៖ ភាពមិនរើសអើង..................................................២៣
- គោលការណ៍ទី៧៖ ការផ្តល់ជំនួយផ្នែកច្បាប់ជាបន្ទាន់ និងប្រកបដោយប្រសិទ្ធភាព ..........................................................២៣
- គោលការណ៍ទី៨៖ សិទ្ធិទទួលបានព័ត៌មាន..........................................២៤
- គោលការណ៍ទី៩៖ ដំណោះស្រាយ និងកិច្ចធានាការពារ..........................២៤
- គោលការណ៍ទី១០៖ សមភាពនៃសិទ្ធិទទួលបានជំនួយផ្នែកច្បាប់.............២៤
- គោលការណ៍ទី១១៖ ជំនួយផ្នែកច្បាប់ដែលជាឧត្តមប្រយោជន៍របស់កុមារ...២៥
- គោលការណ៍ទី១២៖ ឯករាជ្យភាព និងការការពារមន្ត្រីផ្តល់ជំនួយផ្នែកច្បាប់....២៦
- គោលការណ៍ទី១៣៖ សមត្ថភាព និងគណនេយ្យភាព របស់មន្ត្រីក្នុងជំនួយផ្នែកច្បាប់.........................................................២៧
- គោលការណ៍ទី១៤៖ ភាពជាដៃគូ.......................................................២៧

គ. គោលការណ៍ណែនាំ..........................................................................២៨

- គោលការណ៍ណែនាំទី១៖ ការផ្តល់ជំនួយផ្នែកច្បាប់................................២៨
- គោលការណ៍ណែនាំទី២៖ សិទ្ធិទទួលបានព័ត៌មានអំពីជំនួយផ្នែកច្បាប់.......២៩
- គោលការណ៍ណែនាំទី៣៖ សិទ្ធិផ្សេងៗទៀតរបស់ជនដែលត្រូវបានឃុំខ្លួន ចាប់ខ្លួន/ឃាត់ខ្លួន សង្ស័យ ឬជាប់ចោទ ឬក៏ត្រូវបានចោទពីបទល្មើសព្រហ្មទណ្ឌ...............................................៣១
- គោលការណ៍ណែនាំទី៤៖ ជំនួយផ្នែកច្បាប់ នៅដំណាក់កាលមុនពេលជំនុំជម្រះក្តី.................................................៣៣
- គោលការណ៍ណែនាំទី៥៖ ជំនួយផ្នែកច្បាប់ក្នុងកំឡុងពេល ដំណើរការនីតិវិធីតុលាការ..................................................................៣៥
- គោលការណ៍ណែនាំទី៦៖ ជំនួយផ្នែកច្បាប់នៅដំណាក់កាល ក្រោយការជំនុំជម្រះក្តី......................................................................៣៧
- គោលការណ៍ណែនាំទី៧៖ ជំនួយផ្នែកច្បាប់សំរាប់ជនរងគ្រោះ..................៣៩
- គោលការណ៍ណែនាំទី៨៖ ជំនួយផ្នែកច្បាប់សំរាប់សាក្សី...........................៤១
- គោលការណ៍ណែនាំទី៩៖ ការអនុវត្តសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ សំរាប់ស្រ្តី...................................................................................៤៣
- គោលការណ៍ណែនាំទី១០៖ វិធានការពិសេសសំរាប់កុមារ........................៤៣
- គោលការណ៍ណែនាំទី១១៖ ប្រព័ន្ធជំនួយផ្នែកច្បាប់ទូទាំងប្រទេស.............៤៦
- គោលការណ៍ណែនាំទី១២៖ ការផ្តល់មូលនិធិដល់ ប្រព័ន្ធជំនួយផ្នែកច្បាប់ទូទាំងប្រទេស..................................................៥២

- គោលការណ៍ណែនាំទី១៣៖ ធនធានមនុស្ស........................................៥៤
- គោលការណ៍ណែនាំទី១៤៖ អ្នកជំនួយមេធាវី.......................................៥៤
- គោលការណ៍ណែនាំទី១៥៖ លិខិតបទដ្ឋានក្រោមច្បាប់ និងការត្រួតពិនិត្យមើលមន្ត្រីផ្នែកច្បាប់.................................................៥៦
- គោលការណ៍ណែនាំទី១៦៖ ភាពជាដៃគូជាមួយសកលវិទ្យាល័យ និងជាមួយមន្ត្រីផ្តល់សេវាជំនួយផ្នែកច្បាប់ដែលមិនមែនជាមន្ត្រីរដ្ឋ..............៥៧
- គោលការណ៍ណែនាំទី១៧៖ ការស្រាវជ្រាវ និងទិន្នន័យ............................៦០
- គោលការណ៍ណែនាំទី១៨៖ ជំនួយបច្ចេកទេស.....................................៦១

☞☞☞☞@☜☜☜☜

# អង្គការសហប្រជាជាតិ

A/RES/67/187

មហាសន្និបាត

ការចែកចាយៈ ទូទៅ
ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៣

សម័យប្រជុំលើកទី ៦៧
*ចំណុចរបៀបវារៈទី១០៣*

# សេចក្តីសម្រេច
# ត្រូវបានអនុម័តដោយមហាសន្និបាត

[*ស្តីពីរបាយការរបស់គណៈកម្មាធិការទី៣*(A/67/458)]

## គោលការណ៍ និងគោលការណ៍ណែនាំ
## អង្គការសហប្រជាជាតិ
## ស្តីពី
## សិទ្ធិទទួលបានជំនួយផ្នែកច្បាប់
## នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

*មហាសន្និបាត*

*ដោយរំលឹកឡើងវិញ*នូវសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស[១] ដែលតំកល់គោលការណ៍សំខាន់ៗ ស្មើភាពគ្នាចំពោះមុខច្បាប់ និងគោលការណ៍សន្មត់ជាមុនថាគ្មានទោស ក៏ដូចជាសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌ និងជាសាធារណៈ ដែលត្រូវបានធ្វើឡើងដោយសាលាក្តី ប្រកបដោយឯករាជ្យ និងមិនលំអៀង ព្រមជាមួយកិច្ចធានាការពារទាំងអស់ ដែលចាំបាច់សម្រាប់ការពារខ្លួន ជនណាដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ កិច្ចធានាការពារជាអប្បបរមាផ្សេងៗទៀត និងសិទ្ធិត្រូវបានជំនុំជម្រះក្តី ដោយគ្មានការពន្យារពេលមិនសមហេតុផល។

*ដោយរំលឹកឡើងវិញផងដែរ* នូវកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[២] ជាពិសេសត្រង់មាត្រា១៤នៃកតិកាសញ្ញានេះ ដែលចែងថា ជនគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិទទួលបាននូវការជំនុំជម្រះក្តី ដោយមានវត្តមានរបស់ជននោះ និងការពារខ្លួនដោយខ្លួនឯងផ្ទាល់ ឬតាមរយៈជំនួយផ្នែកច្បាប់ ដែលត្រូវបានជ្រើសរើសដោយខ្លួនឯងផ្ទាល់ ឬដែលត្រូវបានចាត់តាំងឲ្យជននោះ ក្នុងករណីផលប្រយោជន៍ផ្នែកយុត្តិធម៌ តម្រូវឲ្យធ្វើដូច្នោះ នៅក្នុងសវនាការប្រកបដោយយុត្តិធម៌ និងជាសាធារណៈ ដោយសាលាក្តីមួយ ដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែលត្រូវបានបង្កើតឡើងដោយច្បាប់។

---

[១] សេចក្តីសម្រេចលេខ ២១៧ A (III) របស់មហាសន្និបាត។

[២] សូមមើលឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ ២២០០ A (XXI) របស់មហាសន្និបាត។

*ដោយចងចាំនូវវិ*ធានបទដ្ឋានអប្បបរមាសម្រាប់គ្រប់គ្រងអ្នកទោស[៣] ដែលត្រូវបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម តាមរយៈសេចក្ដីសម្រេចលេខ៦៦៣C(XXIV) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៥៧ របស់ខ្លួន និងត្រូវបានពង្រីកវិសាលភាព ដោយក្រុមប្រឹក្សានេះ តាមសេចក្ដីសម្រេចលេខ២០៧៦(LXII) ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៧ របស់ខ្លួន ដែលអនុលោមតាមវិធាននេះ ជនជាប់ឃុំដែលមិនទាន់ត្រូវបានជំនុំជម្រះក្ដី សំរាប់គោលបំណងការពារខ្លួន ត្រូវបានអនុញ្ញាតឲ្យទទួលការជួបប្រាស្រ័យទាក់ទងពីសំណាក់ទីប្រឹក្សាច្បាប់របស់ខ្លួន។

*ដោយចងចាំផងដែរ*នូវក្រុមគោលការណ៍សម្រាប់ការពារជនគ្រប់រូបស្ថិតក្រោមទម្រង់ណាមួយនៃការឃុំខ្លួន ឬការកាត់ទោសឲ្យជាប់ពន្ធនាគារ[៤] ត្រង់គោលការណ៍ទី១១ នៃក្រុមគោលការណ៍នេះចែងថា ជនជាប់ឃុំត្រូវមានសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬត្រូវទទួលជំនួយមេធាវីដូចដែលបានបញ្ញត្តដោយច្បាប់។

*ដោយចងចាំថែមទៀត*នូវគោលការណ៍ជាមូលដ្ឋានស្ដីពីតួនាទីរបស់មេធាវី[៥] ជាពិសេសគោលការណ៍ទី៦ នៃគោលការណ៍ជាមូលដ្ឋានដែលចែងថា ជនទាំងឡាយណាគ្មានមេធាវីក្នុងគ្រប់ករណី ដែលផលប្រយោជន៍ផ្នែកយុត្តិធម៌តម្រូវឲ្យធ្វើដូច្នោះ ត្រូវមានសិទ្ធិទទួលបានមេធាវីដែលមានបទ

---

[៣] *សិទ្ធិមនុស្សៈ កម្រងលិខិតុបករណ៍អន្តរជាតវ៉ូលូមទី I* (ភាគទី១) *លិខិតុបករណ៍ជាសកល* (ឯកសារបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ លេខកូដរក្សាសិទ្ធិ E.02.XIV.4 (វ៉ូលូមទីI ភាគទី១)) ត្រង់ផ្នែកទី១J លេខ៣៤។

[៤] ឧបសម្ព័ន្ធនៃសេចក្ដីសម្រេចលេខ 43/173 របស់មហាសន្និបាត ។

[៥] *សមាជអង្គការសហប្រជាជាតិលើកទី៨ ស្ដីពីការបង្ការឧក្រិដ្ឋកម្ម និងការគ្រប់គ្រងជនល្មើស ដែលត្រូវបានរៀបចំធ្វើឡើងនៅរដ្ឋធានីហាវ៉ាណា (Havana) ពីថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩០: របាយការណ៍ ត្រូវបានរៀបចំឡើងដោយលេខាធិការដ្ឋាន* (ឯកសារបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ លេខកូដរក្សាសិទ្ធិ E.91.IV.2) ជំពូក I ផ្នែក B ៣ ជាឧបសម្ព័ន្ធ។

ពិសោធន៍ និងសមត្ថភាព ស្របតាមប្រភេទនៃបទល្មើសដែលត្រូវបានចាត់តាំងសំរាប់ពួកគេ ដើម្បីផ្តល់ជំនួយផ្នែកច្បាប់ប្រកបដោយប្រសិទ្ធភាព ដោយមិនតម្រូវឲ្យពួកគេបង់ប្រាក់ ប្រសិនបើពួកគេ គ្មានមធ្យោបាយគ្រប់គ្រាន់សម្រាប់បង់ថ្លៃសេវាបែបនេះ។

*ដោយរំលឹកឡើងវិញ* នូវសេចក្តីប្រកាសក្រុងបាងកក ស្តីពីសម្ព័ន្ធភាព និងវិធានការឆ្លើយតបៈសម្ព័ន្ធភាពជាយុទ្ធសាស្ត្រក្នុងការបង្ការឧក្រិដ្ឋកម្ម និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ[៦] ជាពិសេសកថាខ័ណ្ឌទី១៨ នៃសេចក្តីប្រកាសនេះ ដែលក្នុងនោះ រដ្ឋសមាជិកតម្រូវឲ្យចាត់វិធានការ អនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួន ដើម្បីលើកស្ទួយសិទ្ធិទទួលបានយុត្តិធម៌ពិនិត្យទៅលើការផ្តល់ជំនួយផ្នែកច្បាប់ ដល់អ្នកដែលត្រូវការជំនួយនេះ និងដើម្បីបង្កលទ្ធភាពទាមទារសិទ្ធិ ប្រកបដោយប្រសិទ្ធភាព ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។

*ដោយរំលឹកឡើងវិញផងដែរ* នូវសេចក្តីប្រកាសក្រុងសាលវ៉ាឌ័រស្តីពីយុទ្ធសាស្ត្រដ៏ទូលំទូលាយ សម្រាប់បញ្ហាប្រឈមជាសកលៈ ការបង្ការឧក្រិដ្ឋកម្ម និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងការអភិវឌ្ឍប្រព័ន្ធនេះ នៅក្នុងពិភពលោកមួយដែលកំពុងមានការផ្លាស់ប្តូរ[៧] ជាពិសេសកថាខ័ណ្ឌទី៥២ នៃសេចក្តីប្រកាសនេះដែលក្នុងនោះបានផ្តល់ជាអនុសាសន៍ថា រដ្ឋសមាជិកត្រូវខំប្រឹងខ្នះខ្នែងកាត់បន្ថយការឃុំខ្លួនបណ្តោះអាសន្នតាមករណីសមស្រប និងលើកស្ទួយការបង្កើនសិទ្ធិទទួលបានយុត្តិធម៌ ព្រមទាំងយន្តការការពារខ្លួនតាមផ្លូវច្បាប់។

---

[៦] សេចក្តីសម្រេចលេខ 60/177 របស់មហាសន្និបាតជាឧបសម្ព័ន្ធ។

[៧] សេចក្តីសម្រេចលេខ 65/230 របស់មហាសន្និបាតជាឧបសម្ព័ន្ធ។

*ដោយរំលឹកឡើងវិញថែមទៀត* នូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម លេខ2007/24 ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិ សំរាប់កែលំអនូវសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសនៅទ្វីបអាហ្វ្រិក។

*ដោយទទួលស្គាល់*ថា ជំនួយផ្នែកច្បាប់ គឺជាធាតុផ្សំចាំបាច់ជាសារវន្តនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌប្រកបដោយយុត្តិធម៌ មនុស្សធម៌ និងប្រសិទ្ធផល ដែលផ្អែកលើនីតិរដ្ឋ និងថាវាជាមូលដ្ឋានគ្រឹះសម្រាប់ការទទួលបានសិទ្ធិផ្សេងៗទៀត ក្នុងនោះរួមមាន សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដែលជាបុរេល័ក្ខខ័ណ្ឌក្នុងការប្រើប្រាស់សិទ្ធិទាំងនេះ និងជាកិច្ចធានាការពារដ៏សំខាន់មួយ ដែលធានាឲ្យមានភាពត្រឹមត្រូវជាមូលដ្ឋាន និងជំនឿទុកចិត្តពីសាធារណៈជន ទៅលើដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។

*ដោយទទួលស្គាល់ផងដែរ*ថាគោលការណ៍និងគោលការណ៍ណែនាំអង្គការសហប្រជាជាតិស្តីពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដែលត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចនេះ អាចត្រូវបានអនុវត្តដោយរដ្ឋសមាជិក ដោយពិចារណាទៅលើប្រព័ន្ធច្បាប់ ដែលមានច្រើនប្រភេទ និងស្ថានភាពសេដ្ឋកិច្ច-សង្គម នៅក្នុងពិភពលោក។

១. *កត់សំគាល់ដោយវាយតម្លៃខ្ពស់*លើការងាររបស់ក្រុមអ្នកជំនាញអន្តររដ្ឋាភិបាល គ្មានដែនកំណត់ស្តីពីការពង្រឹងសិទ្ធិទទួលបានជំនួយផ្នែកច្បាប់នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ នៅក្នុងកិច្ចប្រជុំរបស់ខ្លួន ដែលត្រូវបានរៀបចំធ្វើឡើងនៅទីក្រុងវីយែនកាលពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១ ដើម្បីបង្កើតគោលការណ៍ និងគោលការណ៍ណែនាំមួយសំណុំស្តីពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។

២. *អនុម័ត*គោលការណ៍និងគោលការណ៍ណែនាំអង្គការសហប្រជាជាតិស្តីពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដែលត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចនេះ ជាក្របខ័ណ្ឌដ៏មានប្រយោជន៍សម្រាប់ណែនាំរដ្ឋសមាជិក អំពីគោលការណ៍នានា ដែលប្រព័ន្ធជំនួយផ្នែកច្បាប់ ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ត្រូវតែផ្អែកលើគោលការណ៍ទាំងនេះជាមូលដ្ឋាន ដោយពិចារណាទៅលើខ្លឹមសារនៃសេចក្តីសម្រេចនេះ និងហេតុការណ៍ដែលថា ធាតុផ្សំទាំងអស់មានក្នុងឧបសម្ព័ន្ធនេះ នឹងត្រូវបានអនុវត្តដោយអនុលោមតាមច្បាប់ជាតិ។

៣. ដោយស្របទៅតាមច្បាប់ជាតិរបស់ខ្លួន ស្នើសុំរដ្ឋសមាជិកឲ្យអនុម័ត និងពង្រឹងវិធានការនានា ដើម្បីធានាថា ជំនួយផ្នែកច្បាប់ត្រូវតែបានផ្តល់ឲ្យប្រកបដោយប្រសិទ្ធភាពដោយអនុលោមតាមស្មារតីនៃគោលការណ៍ និងគោលការណ៍ណែនាំទាំងនេះ ដោយចងចាំនូវភាពចម្រុះនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក្នុងចំណោមប្រទេស និងតំបន់ផ្សេងៗគ្នា នៅជុំវិញពិភពលោក និងហេតុការណ៍ដែលថា ជំនួយផ្នែកច្បាប់ ត្រូវតែបានបង្កើតឡើងដោយអនុលោមតាមតុល្យភាពរួម នៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ក៏ដូចជាស្ថានភាពរបស់ប្រទេស និងតំបន់ទាំងនោះ។

៤. *លើកទឹកចិត្ត* ដល់រដ្ឋសមាជិក ឲ្យពិចារណាលើការផ្តល់ជំនួយផ្នែកច្បាប់ និងផ្តល់ជំនួយបែបនេះ ឲ្យបានច្រើនជាអតិបរមា តាមដែលអាចធ្វើទៅបាន ក្នុងករណីសមស្រប។

៥. *លើកទឹកចិត្តផងដែរ* ដល់រដ្ឋសមាជិកឲ្យប្រើប្រាស់គោលការណ៍ និងគោលការណ៍ណែនាំទាំងឡាយតាមការសមស្រប និងដោយអនុលោមតាមច្បាប់ជាតិ ក្នុងកិច្ចខិតខំប្រឹងប្រែង និងចាត់វិធានការថ្នាក់ជាតិ ដើម្បីពង្រឹងសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។

៦. *ស្នើសុំ*ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម ដោយអាស្រ័យទៅលើធនធានថវិកាក្រៅក្របខ័ណ្ឌដែលមាន បន្តផ្តល់សេវាប្រឹក្សាយោបល់ និងជំនួយបច្ចេកទេសដល់រដ្ឋសមាជិកនៅពេលមានការស្នើសុំលើវិស័យកំណែទម្រង់យុត្តិធម៌ព្រហ្មទណ្ឌ ក្នុងនោះរួមមាន ការស្តារយុត្តិធម៌ឡើងវិញ ជម្រើសផ្សេងៗជំនួសឲ្យការដាក់ពន្ធនាគារ និងការរៀបចំបង្កើតផែនការរួម សម្រាប់ការផ្តល់ជំនួយផ្នែកច្បាប់។

៧. *ស្នើសុំផងដែរ* ដល់ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម ដោយអាស្រ័យទៅលើធនធានថវិកាក្រៅក្របខ័ណ្ឌដែលមាន ធ្វើការផ្សព្វផ្សាយគោលការណ៍ និងគោលការណ៍ណែនាំទាំងនេះឲ្យបានទូលំទូលាយ ក្នុងនោះរួមមាន តាមរយៈការបង្កើតឯកសារពាក់ព័ន្ធ ដូចជាសៀវភៅណែនាំ និងសៀវភៅបណ្តុះបណ្តាល។

៨. *ស្នើសុំ* រដ្ឋសមាជិក និងម្ចាស់ជំនួយផ្សេងៗទៀត ផ្តល់ធនធានថវិកាក្រៅក្របខ័ណ្ឌសម្រាប់គោលបំណងនានាដែលត្រូវបានពិពណ៌នាខាងលើ ដោយអនុលោមតាមវិធាន និងនីតិវិធីរបស់អង្គការសហប្រជាជាតិ។

៩. *ស្នើសុំ* អគ្គលេខាធិការអង្គការសហប្រជាជាតិ រាយការណ៍ជូនគណៈកម្មការបង្ការឧក្រិដ្ឋកម្ម និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ នៅក្នុងសម័យប្រជុំលើកទី២៣ របស់ខ្លួន ស្តីពីការអនុវត្តសេចក្តីសម្រេចនេះ។

កិច្ចប្រជុំពេញអង្គលើកទី៦០

ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២

ឧបសម្ព័ន្ធ

**គោលការណ៍ និងគោលការណ៍ណែនាំអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ**

## ក. សេចក្តីផ្តើម

១. ជំនួយផ្នែកច្បាប់ គឺជាធាតុផ្សំជាសារវន្តមួយនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ប្រកបដោយយុត្តិធម៌ មនុស្សធម៌ និងប្រសិទ្ធផល ដែលផ្អែកលើនីតិរដ្ឋជាមូលដ្ឋាន។ ជំនួយផ្នែកច្បាប់ ជាមូលដ្ឋានគ្រឹះសម្រាប់ការទទួលបានសិទ្ធិផ្សេងៗទៀត ក្នុងនោះរួមមាន សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដូចដែលបានកំណត់នៅក្នុងមាត្រា១១ ត្រង់កថាខ័ណ្ឌទី១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ជាបុរេល័ក្ខខ័ណ្ឌក្នុងការប្រើប្រាស់សិទ្ធិទាំងនេះ និងជាកិច្ចធានាការពារដ៏សំខាន់ដែលធានាឲ្យមានភាពយុត្តិធម៌ជាមូលដ្ឋាន និងជំនឿទុកចិត្តពីសាធារណៈលើដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។

២. លើសពីនេះទៅទៀត មាត្រា១៤ កថាខ័ណ្ឌទី៣(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា ក្នុងចំណោមសិទ្ធិផ្សេងៗទៀត ជនគ្រប់រូបត្រូវមានសិទ្ធិ "ទទួលបានការជំនុំជម្រះក្តីដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយខ្លួនឯងផ្ទាល់ ឬតាមរយៈជំនួយផ្នែកច្បាប់ តាមការជ្រើសរើសរបស់ខ្លួន ត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ ហើយត្រូវទទួលបានជំនួយការច្បាប់

ដែលត្រូវចាត់តាំងសំរាប់ខ្លួន ក្នុងករណីណាដែលផលប្រយោជន៍ផ្នែកយុត្តិធម៌ តម្រូវឲ្យធ្វើដូច្នោះ និងដោយឥតបង់ថ្លៃ នៅគ្រប់ករណីបែបនេះ ប្រសិនបើជនជាប់ចោទ គ្មានមធ្យោបាយគ្រប់គ្រាន់ ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ"។

៣. ប្រព័ន្ធជំនួយផ្នែកច្បាប់កំពុងដំណើរការ ដែលជាផ្នែកមួយនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌកំពុងដំណើរការ អាចកាត់បន្ថយថិរវេលាដែលជនសង្ស័យត្រូវបានឃាត់ខ្លួននៅអង្គភាពនគរបាល និងមណ្ឌលឃុំខ្លួន លើសពីនេះអាចកាត់បន្ថយបាននូវចំនួនអ្នកជាប់ពន្ធនាគារ ចំនួនការផ្តន្ទាទោសមិនត្រឹមត្រូវ ភាពចង្អៀតណែននៅតាមពន្ធនាគារ និងការកកស្ទះសំណុំរឿងនៅតុលាការ ព្រមទាំងកាត់បន្ថយការប្រព្រឹត្តបទល្មើសជាថ្មីទៀត និងភាពទទួលរងគ្រោះផ្ទួនៗ។ វាក៏អាចការពារ និងធានាការពារសិទ្ធិរបស់ជនរងគ្រោះ និងសាក្សីនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌផងដែរ។ ជំនួយផ្នែកច្បាប់អាចត្រូវបានប្រើប្រាស់ ដើម្បីរួមចំណែកក្នុងការបង្ការឧក្រិដ្ឋកម្ម ដោយលើកកំពស់ ការយល់ដឹងផ្នែកច្បាប់។

៤. ជំនួយផ្នែកច្បាប់ មានតួនាទីសំខាន់ក្នុងការសម្របសម្រួលយន្តការបង្វែរ និងការប្រើប្រាស់ទណ្ឌកម្ម ព្រមទាំងវិធានការនានានៅតាមសហគមន៍ ក្នុងនោះរួមមានវិធានការមិនឃុំខ្លួន លើកកម្ពស់ការចូលរួមរបស់សហគមន៍ ឲ្យបានកាន់តែច្រើនក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ កាត់បន្ថយការប្រើប្រាស់ដែលមិនចាំបាច់នូវការឃុំខ្លួន និងការកាត់ទោសឲ្យជាប់ពន្ធនាគារ ធ្វើសនិទានកម្មលើគោលនយោបាយយុត្តិធម៌ព្រហ្មទណ្ឌ និងធានាឲ្យមានការប្រើប្រាស់ប្រកបដោយប្រសិទ្ធផលនូវធនធានរបស់រដ្ឋ។

៥. តែគួរឲ្យសោកស្តាយ ប្រទេសជាច្រើននៅខ្វះធនធាន និងសមត្ថភាពចាំបាច់ក្នុងការផ្តល់ជំនួយផ្នែកច្បាប់ដល់ជនសង្ស័យ ជនជាប់ចោទពីការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ជនជាប់ឃុំក្នុងពន្ធនាគារ ជនរងគ្រោះ និងសាក្សី។

៦. គោលការណ៍ និងគោលការណ៍ណែនាំអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដែលដកស្រង់ចេញពីបទដ្ឋានអន្តរជាតិ និងទម្លាប់អនុវត្តន៍ល្អៗដែលត្រូវបានទទួលស្គាល់មានគោលដៅផ្តល់ការណែនាំដល់រដ្ឋនានា អំពីគោលការណ៍ជាមូលដ្ឋានដែលប្រព័ន្ធជំនួយផ្នែកច្បាប់ ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ គួរតែយកធ្វើជាមូលដ្ឋាន ហើយនិងគូសបញ្ជាក់នូវធាតុផ្សំជាក់លាក់ទាំងឡាយ ដែលតម្រូវឲ្យមាន សម្រាប់ប្រព័ន្ធជំនួយផ្នែកច្បាប់ថ្នាក់ជាតិប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ដើម្បីពង្រឹងសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ ដោយអនុលោមតាមសេចក្តីសម្រេចលេខ2007/24 ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ដែលមានចំណងជើងថា "កិច្ចសហប្រតិបត្តិការអន្តរជាតិ សំរាប់កែលំអនូវសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសនៅទ្វីបអាហ្វ្រិក"។

៧. ដោយអនុលោមតាមសេចក្តីប្រកាសក្រុងលីឡុងវី(Lilongwe) ស្តីពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅទ្វីបអាហ្វ្រិក និងផែនការសកម្មភាពក្រុងលីឡុងវី សម្រាប់អនុវត្តន៍សេចក្តីប្រកាសនេះ គោលការណ៍ និងគោលការណ៍ណែនាំទាំងនេះ យកលំនាំតាមគោលគំនិតដ៏ទូលំទូលាយនៃជំនួយផ្នែកច្បាប់។

៨. សម្រាប់គោលបំណងនៃគោលការណ៍ និងគោលការណ៍ណែនាំទាំងនេះ ពាក្យថា "ជំនួយផ្នែកច្បាប់" រួមបញ្ចូលនូវការណែនាំផ្នែកច្បាប់ ជំនួយផ្នែកច្បាប់ និងការធ្វើជាតំណាងសម្រាប់ជនដែលត្រូវបានឃាត់ខ្លួន/ឃុំខ្លួន ត្រូវបានចាប់ខ្លួន ឬត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារ ត្រូវជាប់សង្ស័យ ឬត្រូវជាប់ចោទ ឬក៏ត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ហើយនិងសម្រាប់ជនរងគ្រោះ និងសាក្សីនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ដែលត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃដល់ជនទាំងឡាយណា ដែលគ្មានមធ្យោបាយគ្រប់គ្រាន់ ឬនៅពេលដែលផលប្រយោជន៍ផ្នែកយុត្តិធម៌តម្រូវឲ្យធ្វើដូច្នោះ។ ជាងនេះទៅទៀត "ជំនួយផ្នែកច្បាប់" មានគោលបំណងដាក់បញ្ចូលនូវគោលគំនិតអប់រំផ្នែកច្បាប់ សិទ្ធិទទួលបានព័ត៌មានផ្នែកច្បាប់ និងសេវាផ្សេងៗទៀត ដែលត្រូវបានផ្តល់ជូនដល់ជនទាំងឡាយ តាមរយៈយន្តការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ និងការស្តារដំណើរការយុត្តិធម៌ឡើងវិញ។

៩. សម្រាប់គោលបំណងនៃគោលការណ៍និងគោលការណ៍ណែនាំទាំងនេះ បុគ្គលដែលផ្តល់ជំនួយផ្នែកច្បាប់ ត្រូវបានកំណត់នៅក្នុងនេះថាជា "មន្ត្រីផ្តល់ជំនួយផ្នែកច្បាប់" និងអង្គការទាំងឡាយណាដែលផ្តល់ជំនួយផ្នែកច្បាប់ត្រូវបានកំណត់ថាជា "មន្ត្រីផ្តល់សេវាជំនួយផ្នែកច្បាប់"។ មន្ត្រីផ្តល់ជំនួយផ្នែកច្បាប់ទី១ គឺជាមេធាវី ប៉ុន្តែគោលការណ៍ និងគោលការណ៍ណែនាំទាំងនេះ ក៏ផ្តល់នូវយោបល់ផងដែរថា រដ្ឋទាំងឡាយត្រូវតែធ្វើការជាមួយដៃគូពាក់ព័ន្ធផ្សេងៗ ដែលជាមន្ត្រីផ្តល់សេវាជំនួយផ្នែកច្បាប់ក្នុងទម្រង់ជាអង្គការមិនមែនរដ្ឋាភិបាល អង្គការដែលមានមូលដ្ឋាននៅក្នុងសហគមន៍ អង្គការ

សប្បុរសធម៌បែបសាសនានិងក្រៅក្របខ័ណ្ឌសាសនា ស្ថាប័នវិជ្ជាជីវៈច្បាប់ និងសមាគមនានា ព្រមទាំងស្ថាប័នអប់រំ។ ការផ្តល់ជំនួយផ្នែកច្បាប់ដល់ជនបរទេស ត្រូវតែអនុលោមតាមល័ក្ខខ័ណ្ឌតម្រូវនៃអនុសញ្ញាក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល[៨] និងសន្ធិសញ្ញាទ្វេភាគីដែលអាចអនុវត្តបានផ្សេងផ្សេងទៀត។

១០. គួរកត់សំគាល់ថារដ្ឋទាំងឡាយប្រើប្រាស់គំរូខុសៗគ្នាសម្រាប់ការផ្តល់ជំនួយផ្នែកច្បាប់។ គំរូទាំងនេះ អាចរាប់បញ្ចូល អ្នកការពារក្តីសាធារណៈ មេធាវីឯកជន មេធាវីជាប់កិច្ចសន្យា គម្រោងសេវាផ្នែកច្បាប់ដោយឥតគិតថ្លៃ គណៈមេធាវី អ្នកជំនួយការមេធាវី និងមន្ត្រីផ្សេងៗទៀត។ គោលការណ៍ និងគោលការណ៍ណែនាំទាំងនេះមិនអនុម័តយល់ព្រមលើគំរូជាក់លាក់ណាមួយទេ ប៉ុន្តែលើកទឹកចិត្តដល់រដ្ឋទាំងឡាយ ឲ្យធានាការពារដល់សិទ្ធិជាមូលដ្ឋាន ក្នុងការទទួលបានជំនួយផ្នែកច្បាប់របស់ជនដែលត្រូវបានឃុំខ្លួន ចាប់ខ្លួន ឬត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារ[៩] ត្រូវបានសង្ស័យ[១០] ឬត្រូវចោទ ឬក៏ជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ទន្ទឹមនឹងការពង្រីកវិសាលភាពជំនួយផ្នែកច្បាប់ ដោយរួមបញ្ចូលជនផ្សេងៗទៀត ដែលពាក់ព័ន្ធជាមួយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងធ្វើឲ្យគម្រោងផ្តល់ជំនួយផ្នែកច្បាប់មានភាពចម្រុះគ្នា។

---

[៨] *ស៊េរីសន្ធិសញ្ញា*អង្គការសហប្រជាជាតិ វ៉ូលូមទី ៥៩៦ លេខ 8638។

[៩] ពាក្យថា "ការចាប់ខ្លួន" "ជនដែលត្រូវបានឃុំខ្លួន/ជនជាប់ឃុំ" និង "ជនត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារ " ត្រូវបានស្វែងយល់ដូចដែលបានកំណត់និយមន័យនៅក្នុងក្រុមគោលការណ៍សម្រាប់ការពារជនគ្រប់រូបស្ថិតក្រោមទម្រង់ណាមួយនៃការឃុំខ្លួន ឬការកាត់ទោសឲ្យជាប់ពន្ធនាគារ (សេចក្តីសម្រេចលេខ 43/173 របស់មហាសន្និបាតជាឧបសម្ព័ន្ធ)។

[១០] សិទ្ធិទទួលបានជំនួយផ្នែកច្បាប់របស់ជនសង្ស័យ ត្រូវកើតឡើងនៅមុនពេលសាកសួរយកចម្លើយ គឺនៅពេលដែលពួកគេដឹងថាពួកគេជាកម្មវត្ថុនៃការស៊ើបអង្កេត និងនៅពេលដែលពួកគេស្ថិតនៅក្រោមការគំរាមកំហែងរំលោភបំពាន និងការបំភិតបំភ័យ ឧទាហរណ៍ៈ នៅក្នុងទីកន្លែងឃុំខ្លួន/ឃាត់ខ្លួន។

១១. គោលការណ៍ និងគោលការណ៍ណែនាំទាំងនេះ គឺត្រូវផ្អែកលើការទទួលស្គាល់ថា ក្នុងករណីសមស្រប រដ្ឋទាំងឡាយ ត្រូវតែទទួលរ៉ាប់រងអនុវត្តវិធានការជាសេរី ទោះបីមិនពាក់ព័ន្ធយ៉ាងជិតដល់ទៅនឹងជំនួយផ្នែកច្បាប់ក៏ដោយ ដែលអាចបង្កើនជាអតិបរមានូវឥទ្ធិពលជាវិជ្ជមាន ដែលការបង្កើតឡើង និង/ឬការពង្រឹងប្រព័ន្ធជំនួយផ្នែកច្បាប់កំពុងដំណើរការត្រឹមត្រូវ អាចមានទៅលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ កំពុងដំណើរការត្រឹមត្រូវ និងទៅលើសិទ្ធិទទួលបានយុត្តិធម៌។

១២. ដោយទទួលស្គាល់ថា ក្រុមមនុស្សដោយឡែក ត្រូវមានសិទ្ធិទទួលបានការការពារបន្ថែម បើមិនដូច្នោះទេ ពួកគេកាន់តែប្រឈមនឹងភាពងាយរងគ្រោះផ្ទួនៗ នៅពេលចូលរួមពាក់ព័ន្ធនឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនោះ ទើបគោលការណ៍ និងគោលការណ៍ណែនាំទាំងនេះ មានចែងផងដែរនូវបទប្បញ្ញត្តិជាក់លាក់សំរាប់ស្ត្រី កុមារ និងក្រុមមនុស្សដែលមានសេចក្តីត្រូវការពិសេស។

១៣. គោលការណ៍ និងគោលការណ៍ណែនាំទាំងនេះ ជាបឋម ជាប់ពាក់ព័ន្ធនឹងសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ ដោយមានភាពដោយឡែកពីសិទ្ធិទទួលបានជំនួយឧបត្ថម្ភផ្នែកច្បាប់ ដូចដែលបានទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិ។ គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងគោលការណ៍និងគោលការណ៍ណែនាំទាំងនេះ ត្រូវបានបកស្រាយថាជាការផ្តល់នូវការការពារក្នុងកម្រិតមួយ ទាបជាងការការពារដែលត្រូវបានផ្តល់តាមច្បាប់ជាតិ និងបទដ្ឋាន

ក្រោមជាតិ និងអនុសញ្ញា ឬកតិកាសញ្ញាសិទ្ធិមនុស្សកំរិតអន្តរជាតិ និងកំរិតតំបន់ដែលអាចអនុវត្តបាន ចំពោះការគ្រប់គ្រងវិស័យយុត្តិធម៌ ក្នុងនោះរួមមាន ប៉ុន្តែមិនកម្រិតត្រឹមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុសញ្ញាស្តីពីសិទ្ធិកុមារ[១១] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ[១២] និងអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេឡើយ។[១៣] ទោះជាយ៉ាងណាក៏ដោយ ប្រការនេះមិនត្រូវបានបកស្រាយក្នុងន័យថា រដ្ឋទាំងឡាយត្រូវបានភ្ជាប់កាតព្វកិច្ចដោយលិខិតុបករណ៍កំរិតអន្តរជាតិ និងកំរិតតំបន់ ដែលប្រទេសទាំងនោះមិនបានផ្តល់សច្ចាប័ន ឬចូលជាភាគីនោះទេ។

---

[១១] *សេរីសន្ធិសញ្ញា*អង្គការសហប្រជាជាតិ វ៉ូលូមទី ១៥៧៧ លេខ 27531។

[១២] *សេរីសន្ធិសញ្ញា*អង្គការសហប្រជាជាតិ វ៉ូលូមទី ១២៤៩ លេខ 20378 ។

[១៣] *សេរីសន្ធិសញ្ញា*អង្គការសហប្រជាជាតិ វ៉ូលូមទី ២២២០ លេខ 39481 ។

# ខ. គោលការណ៍

## *គោលការណ៍ទី១៖ សិទ្ធិទទួលបានជំនួយផ្នែកច្បាប់*

១៤. *ដោយទទួលស្គាល់*ថាជំនួយផ្នែកច្បាប់ គឺជាធាតុផ្សំមួយជាសារវន្តនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដែលកំពុងដំណើរការ ផ្អែកលើនីតិរដ្ឋជាមូលដ្ឋាន ដែលជាគ្រឹះមួយ សម្រាប់ការទទួលបាននូវសិទ្ធិផ្សេងៗទៀត ក្នុងនោះរួមមាន សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងជាកិច្ចធានាការពារដ៏សំខាន់ ដែលធានាឲ្យមានភាពយុត្តិធម៌ជាមូលដ្ឋាន និងជំនឿទុកចិត្តពីសាធារណៈជន ទៅលើដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ[១៤] ផងនោះ រដ្ឋទាំងឡាយ ត្រូវតែធានាការពារនូវសិទ្ធិទទួលបានជំនួយផ្នែកច្បាប់នៅក្នុងប្រព័ន្ធច្បាប់ជាតិរបស់ខ្លួន នៅកម្រិតខ្ពស់បំផុត តាមដែលអាចធ្វើបាន រាប់ទាំងនៅក្នុងរដ្ឋធម្មនុញ្ញផង ក្នុងករណីដែលអាចអនុវត្តបាន។

## *គោលការណ៍ទី២៖ ការទទួលខុសត្រូវរបស់រដ្ឋ*

១៥. រដ្ឋទាំងឡាយត្រូវតែចាត់ទុកការផ្តល់ជំនួយផ្នែកច្បាប់ ជាករណីយកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន។ ដើម្បីសម្រេចគោលដៅនេះ តាមករណីសមស្រប រដ្ឋទាំងឡាយត្រូវតែពិនិត្យពិចារណាលើការអនុម័តច្បាប់ និងបទដ្ឋានក្រោមច្បាប់ទាំងឡាយជាក់លាក់ និងធានាថា ប្រព័ន្ធជំនួយផ្នែក

[១៤] វាក្យសព្ទ "ដំណើរការយុត្តិធម៌" ត្រូវបានស្វែងយល់ដូចដែលបានកំណត់និយមន័យ នៅក្នុងគោលការណ៍ណែនាំស្តីពីវិស័យយុត្តិធម៌ក្នុងបញ្ហានានា ពាក់ព័ន្ធនឹងកុមាររងគ្រោះ និងសាក្សីជាកុមារពីឧក្រិដ្ឋកម្ម (ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ 2005/20 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម)។ សម្រាប់គោលបំណងនៃគោលការណ៍ និងគោលការណ៍ណែនាំទាំងនេះ វាក្យសព្ទនេះក៏រួមបញ្ចូលនូវបត្យាប័ន ការផ្ទេរជនជាប់ឃុំក្នុងពន្ធនាគារ និងដំណើរការនីតិវិធីជំនួយឧបត្ថម្ភផ្នែកច្បាប់ទៅវិញទៅមក។

ច្បាប់ដ៏ទូលំទូលាយមួយ ត្រូវតែអនុម័តដាក់ឲ្យដំណើរការដែលអាចទទួលបាន ជាសិទ្ធិប្រកបដោយប្រសិទ្ធភាព មាននិរន្តរភាព និងគួរឲ្យជឿទុកចិត្តបាន។ រដ្ឋទាំងឡាយ ត្រូវតែបែងចែកធនធានមនុស្ស និងធនធានហិរញ្ញវត្ថុចាំបាច់សម្រាប់ប្រព័ន្ធជំនួយផ្នែកច្បាប់នេះ។

១៦. រដ្ឋមិនត្រូវជ្រៀតជ្រែកចូលក្នុងកិច្ចការរបស់អង្គការ ដែលការពារក្តីឲ្យអ្នកទទួលផលពីជំនួយផ្នែកច្បាប់ ឬឯករាជ្យភាពរបស់មន្ត្រីផ្តល់ជំនួយផ្នែកច្បាប់ដល់អ្នកទទួលផលឡើយ។

១៧. រដ្ឋទាំងឡាយត្រូវតែបង្កើនចំណេះដឹងដល់ប្រជាពលរដ្ឋអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេក្រោមច្បាប់ តាមរយៈមធ្យោបាយសមស្រម ដើម្បីបង្ការការប្រព្រឹត្តបទឧក្រិដ្ឋនិងភាពទទួលរងគ្រោះ។

១៨. រដ្ឋទាំងឡាយ ត្រូវតែខំប្រឹងខ្នះខ្នែងបង្កើនចំណេះដឹងដល់សហគមន៍របស់ខ្លួន អំពីវិស័យយុត្តិធម៌ និងមុខងាររបស់វា វិធីដាក់ពាក្យបណ្តឹងនៅចំពោះមុខតុលាការ និងយន្តការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ។

១៩. រដ្ឋទាំងឡាយ ត្រូវតែពិចារណាលើការអនុម័តវិធានការសមស្របសម្រាប់ផ្តល់ព័ត៌មានដល់សហគមន៍របស់ខ្លួន អំពីអំពើដែលត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌតាមច្បាប់។ ការផ្តល់ព័ត៌មានបែបនេះ ដល់អ្នកធ្វើដំណើរទៅក្នុងដែនសមត្ថកិច្ចផ្សេងៗទៀត ក្នុងករណីដែលបទល្មើសព្រហ្មទណ្ឌត្រូវបានចាត់ថ្នាក់តាមប្រភេទ និងកាត់ទោស តាមរបៀបខុសៗគ្នា គឺមានភាពចាំបាច់សម្រាប់បង្ការទប់ស្កាត់ឧក្រិដ្ឋកម្ម។

## *គោលការណ៍ទី៣៖ ជំនួយផ្នែកច្បាប់សម្រាប់ជនដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ*

២០. រដ្ឋទាំងឡាយ ត្រូវតែធានាថា ជនគ្រប់រូបដែលត្រូវបានចាប់ខ្លួន ឃុំខ្លួន សង្ស័យ ឬត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌដែលអាចត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ឬទោសប្រហារជីវិត ត្រូវមានសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ នៅគ្រប់ដំណាក់កាលនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។

២១. ជំនួយផ្នែកច្បាប់ ត្រូវតែផ្តល់ឲ្យផងដែរ ដោយមិនគិតពីមធ្យោបាយរបស់ជននោះ ប្រសិនបើផលប្រយោជន៍ផ្នែកយុត្តិធម៌តម្រូវឲ្យធ្វើដូច្នោះ តួយ៉ាងដូចជា ដោយសារតែភាពបន្ទាន់ ឬភាពសាំញ៉ាំនៃរឿងក្តី ឬភាពធ្ងន់ធ្ងរនៃទោសជាសក្តានុពល។

២២. កុមារត្រូវមានសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ តាមល័ក្ខខ័ណ្ឌដូចគ្នានឹង ឬល័ក្ខខ័ណ្ឌអត់ឱនច្រើនជាងមនុស្សពេញវ័យ។

២៣. វាជាការទទួលខុសត្រូវរបស់មន្ត្រីនគរបាល ព្រះរាជអាជ្ញា និងចៅក្រមក្នុងការធានាថា ជនទាំងឡាយដែលបង្ហាញខ្លួននៅចំពោះមុខពួកគេ ដែលមិនមានលទ្ធភាពរកបានមេធាវី និង/ឬដែលពួកគេជាជនងាយរងគ្រោះ ត្រូវបានផ្តល់នូវលទ្ធភាពទទួលបានជំនួយផ្នែកច្បាប់។

## *គោលការណ៍ទី៤៖ ជំនួយផ្នែកច្បាប់សម្រាប់ជនរងគ្រោះពីឧក្រិដ្ឋកម្ម*

២៤. ដោយមិនប៉ះពាល់ដល់ ឬមិនមែនមិនស្របទៅនឹងសិទ្ធិរបស់ជនជាប់ចោទ រដ្ឋទាំងឡាយ ត្រូវតែផ្តល់ជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះពីឧក្រិដ្ឋតាមករណីសមស្រប។

## គោលការណ៍ទី៥៖ ជំនួយផ្នែកច្បាប់សម្រាប់សាក្សី

២៥. ដោយមិនប៉ះពាល់ដល់ ឬមិនមែនមិនស្របទៅនឹងសិទ្ធិរបស់ជនជាប់ចោទ រដ្ឋទាំងឡាយត្រូវតែផ្តល់ជំនួយផ្នែកច្បាប់ ដល់សាក្សីពីឧក្រិដ្ឋកម្មតាមករណីសមស្រប។

## គោលការណ៍ទី៦៖ ភាពមិនរើសអើង

២៦. រដ្ឋទាំងឡាយ ត្រូវតែធានាឲ្យមានការផ្តល់ជំនួយផ្នែកច្បាប់ ដល់ជនគ្រប់រូប ដោយមិនគិតពីអាយុ ជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ឬជំនឿ ទស្សនៈនយោបាយ ឬទស្សនៈផ្សេងៗទៀត ដើមកំណើតជាតិ ឬដើមកំណើតសង្គម ទ្រព្យសម្បត្តិ សញ្ជាតិ ឬលំនៅដ្ឋានកំណើត ការអប់រំ ឬឋានៈក្នុងសង្គម ឬឋានៈផ្សេងផ្សេងទៀត។

## គោលការណ៍ទី៧៖ ការផ្តល់ជំនួយផ្នែកច្បាប់ជាបន្ទាន់ និងប្រកបដោយប្រសិទ្ធភាព

២៧. រដ្ឋទាំងឡាយ ត្រូវធានាថា ជំនួយផ្នែកច្បាប់ប្រកបដោយប្រសិទ្ធភាព ត្រូវតែបានផ្តល់ឲ្យជាបន្ទាន់ នៅគ្រប់ដំណាក់កាលនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។

២៨. ជំនួយផ្នែកច្បាប់ប្រកបដោយប្រសិទ្ធភាព រួមមាន ប៉ុន្តែមិនកម្រិតត្រឹមសិទ្ធិក្នុងការប្រាស្រ័យទាក់ទងជាមួយមន្ត្រីផ្តល់ជំនួយផ្នែកច្បាប់ ដោយគ្មានការរារាំងសម្រាប់ជនជាប់ឃុំទាំងឡាយ សិទ្ធិរក្សាការសម្ងាត់ក្នុងការធ្វើទំនាក់ទំនង សិទ្ធិក្នុងការពិនិត្យសំណុំរឿង និងសិទ្ធិមានពេលវេលា និងលទ្ធភាពគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការពារខ្លួនសំរាប់ពួកគេ។

## *គោលការណ៍ទី៨៖ សិទ្ធិទទួលបានព័ត៌មាន*

២៩. រដ្ឋទាំងឡាយត្រូវធានាថាមុនពេលសាកសួរយកចម្លើយ និងនៅពេលដកហូតសិទ្ធិសេរីភាព ជនទាំងឡាយត្រូវទទួលបាននូវព័ត៌មានស្តីពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់របស់ខ្លួននិងកិច្ចធានាការពារតាមនីតិវិធីផ្សេងៗទៀត ក៏ដូចជាស្តីពីផលវិបាកជាសក្តានុពលក្នុងការបោះបង់ដោយស្ម័គ្រចិត្តនូវសិទ្ធិទាំងនោះ។

៣០. រដ្ឋទាំងឡាយត្រូវធានាថាព័ត៌មានស្តីពីសិទ្ធិនៅក្នុងអំឡុងពេលដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ និងសេវាជំនួយផ្នែកច្បាប់ ត្រូវធ្វើការផ្សព្វផ្សាយដោយសេរី និងអាចផ្តល់នូវលទ្ធភាពទទួលបានដល់សាធារណជន។

## *គោលការណ៍ទី៩៖ ដំណោះស្រាយ និងកិច្ចធានាការពារ*

៣១. រដ្ឋទាំងឡាយត្រូវបង្កើតដំណោះស្រាយ និងកិច្ចធានាការពារដែលត្រូវអនុវត្ត ប្រសិនបើសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ ត្រូវបានធ្វើឲ្យអន្តរាយពន្យារពេល ឬបដិសេធ ឬប្រសិនបើជនទាំងឡាយ មិនត្រូវបានគេផ្តល់នូវព័ត៌មានគ្រប់គ្រាន់ ស្តីពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់របស់ខ្លួន។

## *គោលការណ៍ទី១០៖ សមភាពនៃសិទ្ធិទទួលបានជំនួយផ្នែកច្បាប់*

៣២. វិធានការពិសេសទាំងឡាយ ត្រូវតែចាត់ឲ្យមានឡើង ដើម្បីធានាបាននូវសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ប្រកបដោយអត្ថន័យសម្រាប់ស្ត្រី កុមារ និងក្រុមមនុស្សដែលមានតម្រូវការពិសេស ក្នុងនោះរួមមាន ប៉ុន្តែមិនកម្រិត

ត្រឹមមនុស្សចាស់ ជនភាគតិច ជនពិការ ជនវិកលចរិត អ្នកផ្ទុកមេរោគអេដស៍ និងអ្នកមានជំងឺឆ្លងធ្ងន់ធ្ងរផ្សេងៗទៀត អ្នកប្រើប្រាស់គ្រឿងញៀន ជនជាតិដើមភាគតិច និងជនអម្បូរដើម ជនគ្មានសញ្ជាតិ អ្នកសុំសិទ្ធិជ្រកកោន ជនបរទេស ជននិរប្រវេសន៍ និងពលករទេសន្តរប្រវេសន៍ ជនភៀសខ្លួន និងជនចំណាកស្រុក នៅក្នុងប្រទេសឡើយ។ វិធានការបែបនេះ គួរតែលើកសេចក្តីត្រូវការពិសេសរបស់ក្រុមមនុស្សទាំងនេះ យកមកដោះស្រាយ ក្នុងនោះ រួមមានវិធានការផ្តោតលើយេនឌ័រ និងវិធានការសមស្របតាមអាយុ។

៣៣. រដ្ឋទាំងឡាយត្រូវធានាផងដែរថា ជំនួយផ្នែកច្បាប់ ត្រូវតែបានផ្តល់ដល់អ្នករស់នៅតំបន់ជនបទ តំបន់ដាច់ស្រយាល និងតំបន់ដែលមានវិបត្តិខាងសេដ្ឋកិច្ច និងសង្គមកិច្ច និងដល់អ្នកដែលជាសមាជិកនៃក្រុមមនុស្សដែលមានវិបត្តិខាងសេដ្ឋកិច្ច និងសង្គមកិច្ច។

## *គោលការណ៍ទី១១៖ ជំនួយផ្នែកច្បាប់ ដែលជាឧត្តមប្រយោជន៍របស់កុមារ*

៣៤. នៅក្នុងការសម្រេចលើជំនួយផ្នែកច្បាប់ទាំងអស់ ដែលប៉ះពាល់ដល់កុមារ[១៥] ត្រូវគិតគូរដល់ឧត្តមប្រយោជន៍របស់កុមារ។

៣៥. ជំនួយផ្នែកច្បាប់ ដែលត្រូវបានផ្តល់ដល់កុមារ ត្រូវតែកំណត់ជាអាទិភាព ដោយគិតគូរដល់ឧត្តមប្រយោជន៍របស់កុមារ និងអាចផ្តល់នូវលទ្ធភាពទទួលបានសមស្របតាមអាយុ ជាអន្តរវិស័យ ប្រកបដោយប្រសិទ្ធភាព និងឆ្លើយតបទៅនឹងសេចក្តីត្រូវការផ្នែកច្បាប់ និងផ្នែកសង្គមជាក់លាក់របស់កុមារ។

១៥ "កុមារ" មានន័យថា ជាបុគ្គលណាក៏ដោយដែលមានអាយុក្រោម១៨ឆ្នាំ ស្របតាមអនុសញ្ញាសន្ដីពីសិទ្ធិកុមារ

## *គោលការណ៍ទី១២៖ ឯករាជ្យភាព និងការការពារមន្ត្រីផ្តល់ជំនួយផ្នែកច្បាប់*

៣៦. រដ្ឋទាំងឡាយត្រូវធានាថាមន្ត្រីផ្តល់ជំនួយផ្នែកច្បាប់អាចអនុវត្តការងាររបស់ពួកគេបានប្រកបដោយប្រសិទ្ធភាព ដោយសេរី និងដោយឯករាជ្យ។ ជាពិសេស រដ្ឋទាំងឡាយត្រូវធានាថាអ្នកផ្តល់ជំនួយផ្នែកច្បាប់ អាចបំពេញមុខងារវិជ្ជាជីវៈច្បាប់ទាំងអស់របស់ពួកគេបាន ដោយគ្មានការបំភិតបំភ័យ ឧបសគ្គរារាំង ការយាយីរំខាន ឬការជ្រៀតជ្រែកដែលមិនសមស្រប អាចធ្វើដំណើរពិគ្រោះយោបល់ និងជួបជាមួយអតិថិជនរបស់ពួកគេដោយសេរី និងដោយសម្ងាត់ទាំងស្រុង ទាំងនៅក្នុងប្រទេសរបស់ខ្លួនគេផ្ទាល់ និងនៅក្រៅប្រទេស និងពិនិត្យមើលការចោទប្រកាន់ និងសំណុំរឿងពាក់ព័ន្ធផ្សេងៗទៀតដោយសេរី ព្រមទាំងមិនទទួលរងនូវ និងមិនត្រូវបានគំរាមកំហែងចោទប្រកាន់ ឬការដាក់ទោសទណ្ឌផ្នែករដ្ឋបាល សេដ្ឋកិច្ច ឬការដាក់ទោសទណ្ឌផ្សេងៗទៀតចំពោះវិធានការណាមួយ ដែលត្រូវបានអនុវត្ត ដោយអនុលោមតាមករណីយកិច្ច បទដ្ឋាន និងសីលធម៌វិជ្ជាជីវៈដែលត្រូវបានទទួលស្គាល់ឡើយ។

## *គោលការណ៍ទី១៣៖ សមត្ថភាព និងគណនេយ្យភាពរបស់មន្ត្រីផ្តល់ជំនួយផ្នែកច្បាប់*

៣៧. រដ្ឋទាំងឡាយត្រូវដាក់ឲ្យដំណើរការនូវយន្តការទាំងឡាយ ដើម្បីធានាថាមន្ត្រីផ្តល់ជំនួយផ្នែកច្បាប់ទាំងអស់ ត្រូវមានការអប់រំ ការបណ្តុះបណ្តាលជំនាញ និងបទពិសោធន៍សមស្របនឹងប្រភេទនៃការងាររបស់ពួកគេ ក្នុងនោះរួមមាន ភាពធ្ងន់ធ្ងរនៃបទល្មើសដែលត្រូវដោះស្រាយ ព្រមទាំងសិទ្ធិ និងសេចក្តីត្រូវការរបស់ស្ត្រី កុមារ និងក្រុមមនុស្ស ដែលមានសេចក្តីត្រូវការពិសេស។

៣៨. ពាក្យបណ្តឹងពាក់ព័ន្ធនឹងវិន័យប្រឆាំងនឹងមន្ត្រីផ្តល់ជំនួយផ្នែកច្បាប់ទាំងឡាយត្រូវតែធ្វើការស៊ើបអង្កេត និងវិនិច្ឆ័យទោសជាបន្ទាន់ ដោយអនុលោមតាមក្រមសីលធម៌វិជ្ជាជីវៈនៅចំពោះមុខស្ថាប័នមួយដែលមិនលំអៀង និងអាចពិនិត្យឡើងវិញតាមផ្លូវតុលាការ។

## *គោលការណ៍ទី១៤៖ ភាពជាដៃគូ*

៣៩. រដ្ឋទាំងឡាយគួរតែទទួលស្គាល់ និងលើកទឹកចិត្តដល់ការចូលរួមចំណែកពីសមាគមមេធាវី សកលវិទ្យាល័យ សង្គមស៊ីវិល និងក្រុមផ្សេងៗ ព្រមទាំងស្ថាប័នផ្សេងៗទៀត ក្នុងការផ្តល់ជំនួយផ្នែកច្បាប់។

៤០. ក្នុងករណីចាំបាច់ ភាពជាដៃគូក្នុងទម្រង់ជាសាធារណៈ-ឯកជន និងភាពជាដៃគូផ្សេងៗទៀត គួរតែត្រូវបានបង្កើតឡើង ដើម្បីពង្រីកវិសាលភាពជំនួយផ្នែកច្បាប់នេះ។

## គ. គោលការណ៍ណែនាំ

### *គោលការណ៍ណែនាំទី១៖ ការផ្តល់ជំនួយផ្នែកច្បាប់*

៤១. នៅពេលណា រដ្ឋទាំងឡាយអនុវត្តយន្តការផ្ទៀងផ្ទាត់ពីភាពក្រីក្រដើម្បីកំណត់អំពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ រដ្ឋទាំងឡាយនោះត្រូវធានាថា៖

(ក) ជនទាំងឡាយដែលមធ្យោបាយរបស់ខ្លួន មានលើសពីកម្រិតកំណត់នៃយន្តការផ្ទៀងផ្ទាត់ពីភាពក្រីក្រ ប៉ុន្តែពួកគេមិនអាចមានលទ្ធភាពរក ឬមិនមានលទ្ធភាពទទួលបានមេធាវី នៅក្នុងស្ថានភាពដែលជំនួយផ្នែកច្បាប់ ត្រូវបានផ្តល់ជូនតាមបែបផ្សេងពីនេះ និងជាផលប្រយោជន៍ផ្នែកយុត្តិធម៌ដែលត្រូវផ្តល់ជំនួយបែបនេះ មិនត្រូវបានផាត់ចេញពីការទទួលជំនួយនេះឡើយ។

(ខ) លក្ខណៈវិនិច្ឆ័យសម្រាប់ការអនុវត្តយន្តការផ្ទៀងផ្ទាត់ពីភាពក្រីក្រត្រូវផ្សព្វផ្សាយឲ្យបានទូលំទូលាយ។

(គ) ជនទាំងឡាយដែលត្រូវការជាបន្ទាន់ នូវជំនួយផ្នែកច្បាប់នៅអង្គភាពនគរបាល មណ្ឌលឃុំខ្លួនឬតុលាការ គួរតែត្រូវបានផ្តល់ជំនួយផ្នែកច្បាប់ដំបូង ខណៈដែលសិទ្ធិក្នុងការទទួលរបស់ពួកគេកំពុងត្រូវបានកំណត់។ អនីតិជន ជានិច្ចកាលត្រូវបានលើកលែងពីយន្តការផ្ទៀងផ្ទាត់ពីភាពក្រីក្រនេះ។

(ឃ) ជនទាំងឡាយ ដែលត្រូវបានបដិសេធជំនួយផ្នែកច្បាប់ ដោយឈរលើមូលដ្ឋានយន្តការផ្ទៀងផ្ទាត់ពីភាពក្រីក្រមានសិទ្ធិប្តឹងតវ៉ានឹងសេចក្តីសម្រេចនេះ។

(ង) ដោយយកចិត្តទុកដាក់ចំពោះស្ថានភាពដោយឡែករបស់បុគ្គល និងបន្ទាប់ពីពិចារណាទៅលើមូលហេតុនៃការបដិសេធរបស់គេចំពោះជំនួយផ្នែកច្បាប់ តុលាការបង្គាប់ថា បុគ្គលនោះត្រូវតែបានផ្តល់ជំនួយផ្នែកច្បាប់ដោយមាន ឬគ្មានការរួមវិភាគទានពីបុគ្គលនោះ នៅពេលដែលផលប្រយោជន៍ផ្នែកយុត្តិធម៌តម្រូវឲ្យធ្វើដូច្នោះ។

(ច) ប្រសិនបើយន្តការផ្ទៀងផ្ទាត់ពីភាពក្រីក្រត្រូវបានគណនាដោយឈរលើមូលដ្ឋានប្រាក់ចំណូលសម្រាប់សមាជិកគ្រួសារ ប៉ុន្តែសមាជិកម្នាក់ម្នាក់នៃគ្រួសារមានទំនាស់ផលប្រយោជន៍ជាមួយគ្នា ឬមិនមានលទ្ធភាពស្មើគ្នា ក្នុងការទទួលបានប្រាក់ចំណូលរបស់គ្រួសារនោះ យកតែប្រាក់ចំណូលរបស់សមាជិក ដែលដាក់ពាក្យសុំជំនួយផ្នែកច្បាប់ប៉ុណ្ណោះ ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនៃយន្តការផ្ទៀងផ្ទាត់ពីភាពក្រីក្រនេះ។

## *គោលការណ៍ណែនាំទី២៖ សិទ្ធិទទួលបានព័ត៌មានអំពីជំនួយផ្នែកច្បាប់*

៤២. ដើម្បីធានាដល់ជនទាំងឡាយ នូវសិទ្ធិទទួលបានព័ត៌មានអំពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់របស់ពួកគេ រដ្ឋទាំងឡាយត្រូវធានាថា៖

(ក) ព័ត៌មានអំពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ និងអ្វីផ្សេងទៀតដែលជាជំនួយបែបនេះមាន ក្នុងនោះរួមមាន អត្ថិភាពនៃសេវាជំនួយផ្នែកច្បាប់ និងវិធីទទួលបាននូវសេវាបែបនេះ ព្រមទាំងព័ត៌មានពាក់ព័ន្ធផ្សេងៗទៀត ត្រូវធ្វើការផ្សព្វផ្សាយដល់សហគមន៍ និងសាធារណជនទូទៅ នៅតាមការិយាល័យរដ្ឋាភិបាលមូលដ្ឋាន និងគ្រឹះស្ថានអប់រំ និងសាសនា និងតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ក្នុងនោះរួមមានអ៊ិនធើណិត ឬមធ្យោបាយសមស្របផ្សេងៗទៀត។

(ខ) ព័ត៌មានត្រូវតែធ្វើការផ្សព្វផ្សាយដល់ក្រុមមនុស្សឯកោ និងក្រុមមនុស្សទន់ខ្សោយ។ ត្រូវប្រើប្រាស់កម្មវិធីវិទ្យុ និងទូរទស្សន៍ សារព័ត៌មានប្រចាំតំបន់ និងក្នុងស្រុក អ៊ិនធើណិត និងមធ្យោបាយផ្សេងៗទៀត ជាពិសេស បន្ទាប់ពីមានការធ្វើវិសោធនកម្មច្បាប់ ឬលើកឡើងនូវបញ្ហាជាក់លាក់ដែលប៉ះពាល់ដល់សហគមន៍ ដោយកំណត់យកកិច្ចប្រជុំតាមសហគមន៍ជាគោលដៅ។

(គ) មន្ត្រីនគរបាល ព្រះរាជអាជ្ញា មន្ត្រីតុលាការ និងមន្ត្រីបំរើការនៅតាមស្ថាប័នដែលជនទាំងឡាយត្រូវបានឃុំខ្លួនក្នុងពន្ធនាគារ ឬឃាត់ខ្លួនត្រូវផ្តល់ដល់ជនទាំងឡាយដែលគ្មានតំណាង នូវព័ត៌មានអំពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់របស់ពួកគេ និងអំពីកិច្ចធានាការពារតាមនីតិវិធីផ្សេងៗទៀត។

(ឃ) ព័ត៌មានអំពីសិទ្ធិរបស់ជនដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌ នៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ និងអំពីភាពដែលអាចរកបាននូវសេវាជំនួយផ្នែកច្បាប់ ត្រូវតែផ្តល់ដល់អង្គភាពនគរបាលមណ្ឌលឃុំខ្លួន តុលាការ និងពន្ធនាគារ ឧទា. តាមរយៈការផ្តល់ឯកសារ (លិខិត) អំពីសិទ្ធិទាំងឡាយ ឬតាមទម្រង់ផ្លូវការណាមួយផ្សេងទៀត ដែលត្រូវប្រគល់ឲ្យទៅជនជាប់ចោទ។ ព័ត៌មានបែបនេះ គួរតែត្រូវបានផ្តល់តាមរបៀបមួយ ដែលស្របនឹងសេចក្តីត្រូវការរបស់ជនមិនចេះអក្សរ ជនជាតិភាគតិច ជនពិការ និងកុមារ ហើយព័ត៌មានបែបនេះ គួរតែប្រើប្រាស់ជាភាសា ដែលជនទាំងនោះយល់បាន។ ព័ត៌មានដែលត្រូវផ្តលដល់កុមារ ត្រូវតែបានផ្តល់តាមរបៀបមួយ ដែលសមស្របទៅនឹងអាយុ និងភាពចាស់ទុំរបស់ពួកគេ។

(ង) ដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ត្រូវតែមានសម្រាប់ជនទាំងឡាយដែលមិនត្រូវបាន ផ្ដល់នូវព័ត៌មានគ្រប់គ្រាន់អំពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់របស់ពួកគេ។ ដំណោះស្រាយបែបនេះអាចរួមបញ្ចូល ការហាមឃាត់មិនឲ្យបំពេញកិច្ចតាមនីតិវិធី ការដោះលែងពីការឃុំខ្លួន ការបដិសេធចោលនូវភស្តុតាង ការពិនិត្យឡើងវិញតាមផ្លូវតុលាការ និងការទូទាត់សំណង។

(ច) មធ្យោបាយផ្ទៀងផ្ទាត់ ដែលបញ្ជាក់ថា បុគ្គលពិតជាត្រូវបានផ្ដល់ព័ត៌មាន ត្រូវតែបានដាក់ឲ្យដំណើរការ។

## *គោលការណ៍ណែនាំទី៣៖ សិទ្ធិផ្សេងៗទៀតរបស់ជនដែលត្រូវបានឃុំខ្លួន ចាប់ខ្លួន/ឃាត់ខ្លួន សង្ស័យ ឬជាប់ចោទ ឬក៏ត្រូវបានចោទពីបទល្មើសព្រហ្មទណ្ឌ*

៤៣. រដ្ឋទាំងឡាយត្រូវតែដាក់ចេញនូវវិធានការនានាដូចខាងក្រោមដើម្បី៖

(ក) ផ្ដល់ជាបន្ទាន់ដល់បុគ្គលគ្រប់រូបដែលត្រូវបានឃុំខ្លួន ចាប់ខ្លួន/ឃាត់ខ្លួន សង្ស័យ ឬត្រូវបានចោទប្រកាន់ ឬក៏ត្រូវបានជាប់ចោទពីបទល្មើសព្រហ្មទណ្ឌនូវព័ត៌មានស្ដីពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប សិទ្ធិពិគ្រោះយោបល់ជាមួយមេធាវី ឬប្រសិនបើអាចធ្វើបាន ត្រូវពិគ្រោះយោបល់ជាមួយមន្ត្រីផ្ដល់ជំនួយផ្នែកច្បាប់ នៅដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធី ជាពិសេស មុនពេលត្រូវបានសាកសួរយកចម្លើយដោយអាជ្ញាធរ និងសិទ្ធិទទួលបានជំនួយពីមេធាវីដោយឯករាជ្យ ឬពីមន្ត្រីផ្ដល់ជំនួយផ្នែកច្បាប់ នៅពេលត្រូវគេសាកសួរយកចម្លើយ និងនៅអំឡុងពេលបំពេញកិច្ច តាមនីតិវិធីផ្សេងៗទៀត។

(ខ) ហាមឃាត់ការសាកសួរយកចម្លើយណាមួយចំពោះបុគ្គល ដែលត្រូវធ្វើឡើងដោយនគរបាល ដោយគ្មានវត្តមានមេធាវី ទោះជាស្ថិតក្រោមស្ថានភាពមិនបង្ខិតបង្ខំក៏ដោយ លើកលែងតែជននោះផ្តល់នូវការព្រមព្រៀងរបស់គេដែលត្រូវបានប្រាប់ឲ្យដឹង និងដោយស្ម័គ្រចិត្តក្នុងការបោះបង់ចោលសិទ្ធិមានវត្តមានមេធាវី និងបង្កើតយន្តការនានា សម្រាប់ផ្ទៀងផ្ទាត់ការព្រមព្រៀងជាប្រភេទស្ម័គ្រចិត្តរបស់ជននោះ។ ការសាកសួរយកចម្លើយ មិនត្រូវចាប់ផ្តើមធ្វើទេ លុះត្រាតែមន្ត្រីផ្តល់ជំនួយផ្នែកច្បាប់មកដល់។

(គ) ផ្តល់ព័ត៌មានដល់ជនជាប់ឃុំ និងអ្នកទោសជាជនបរទេសទាំងអស់ ជាភាសាដែលពួកគេយល់បាន អំពីសិទ្ធិរបស់ពួកគេ ក្នុងការស្នើសុំធ្វើទំនាក់ទំនងជាមួយអាជ្ញាធរកុងស៊ុលរបស់ពួកគេដោយគ្មានការពន្យារពេល។

(ឃ) ធានាថាជនទាំងឡាយជួបមេធាវី ឬមន្ត្រីផ្តល់ជំនួយផ្នែកច្បាប់ជាបន្ទាន់ ដោយសម្ងាត់ទាំងស្រុង បន្ទាប់ពីការចាប់ខ្លួនរបស់ពួកគេ និងថាការសម្ងាត់នៃទំនាក់ទំនងបន្តទៀតត្រូវតែបានធានា។

(ង) បង្កលទ្ធភាពឲ្យបុគ្គលគ្រប់រូប ដែលត្រូវបានឃុំខ្លួនដោយសារមូលហេតុណាមួយ ជូនដំណឹងជាបន្ទាន់ដល់សមាជិកគ្រួសាររបស់ពួកគេ ឬបុគ្គលដែលសមស្របផ្សេងទៀត តាមការជ្រើសរើសរបស់ពួកគេ អំពីការឃុំខ្លួន និងទីកន្លែងឃុំខ្លួន ហើយនឹងអំពីការផ្លាស់ប្តូរទីកន្លែងឃុំខ្លួនដែលនឹងអាចកើតមានឡើង។ ទោះបីយ៉ាងណាក៏ដោយ អាជ្ញាធរមានសមត្ថកិច្ចអាចពន្យារពេលការជូនដំណឹង ប្រសិនបើមានការចាំបាច់ណាស់ ប្រសិនបើមានចែងដោយច្បាប់ និងប្រសិនបើការបញ្ជូនព័ត៌មាននេះ នឹងរារាំងដល់ការស៊ើបអង្កេតលើបទល្មើសព្រហ្មទណ្ឌនោះ។

(ច) ផ្តល់នូវសេវាបកប្រែផ្ទាល់មាត់ដោយអ្នកបកប្រែឯករាជ្យនៅពេលណាចាំបាច់ ព្រមទាំងផ្តល់សេវាបកប្រែឯកសារក្នុងករណីសមស្រប។

(ឆ) ចាត់តាំងអាណាព្យាបាល នៅពេលណាចាំបាច់។

(ជ) ធ្វើការផ្សព្វផ្សាយ អំពីមធ្យោបាយទំនាក់ទំនង ជាមួយមន្ត្រីផ្តល់ជំនួយផ្នែកច្បាប់ នៅតាមអង្គភាពនគរបាល និងទីកន្លែងឃុំខ្លួន។

(ឈ) ធានាថាជនទាំងឡាយដែលត្រូវបានឃុំខ្លួន/ចាប់ខ្លួន សង្ស័យ ឬត្រូវបានចោទប្រកាន់ ឬត្រូវបានជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវតែបានប្រាប់ឲ្យដឹងយ៉ាងច្បាស់ និងងាយយល់អំពីសិទ្ធិរបស់ពួកគេ និងបច្ច័យមិនល្អក្នុងការបោះបង់ចោលសិទ្ធិទាំងនេះ និងខំប្រឹងខ្នះខ្នែងធានាថា ជនទាំងឡាយយល់ដឹងពីករណីទាំងពីរនេះ។

(ញ) ធានាថា ជនទាំងឡាយត្រូវបានផ្តល់ព័ត៌មាន អំពីយន្តការណាមួយ ដែលអាចរកបានសម្រាប់ដាក់ពាក្យបណ្តឹងអំពីការធ្វើទារុណកម្ម ឬប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន។

(ដ) ធានាថា ការប្រើប្រាស់សិទ្ធិទាំងនេះដោយបុគ្គល មិនធ្វើឲ្យប៉ះពាល់ដល់រឿងក្តីរបស់ពួកគេឡើយ។

## *គោលការណ៍ណែនាំទី៤៖ ជំនួយផ្នែកច្បាប់នៅដំណាក់កាលមុនពេលជំនុំជម្រះក្តី*

៤៤. ដើម្បីធានាថាជនដែលត្រូវបានឃុំខ្លួនមានសិទ្ធិទទួលជំនួយផ្នែកច្បាប់ជាបន្ទាន់ ដោយអនុលោមតាមច្បាប់នោះ រដ្ឋទាំងឡាយត្រូវចាត់វិធានការដូចតទៅដើម្បី៖

(ក) ធានាថានគរបាល និងអាជ្ញាធរតុលាការមិនត្រូវរឹតត្បិតសិទ្ធិ ឬលទ្ធភាពទទួលបានជំនួយផ្នែកច្បាប់តាមទំនើងចិត្ត សម្រាប់ជនទាំងឡាយដែលត្រូវបានឃុំខ្លួន ចាប់ខ្លួន សង្ស័យ ឬត្រូវបានចោទប្រកាន់ ឬក៏ត្រូវបានជាប់ចោទពីបទល្មើសព្រហ្មទណ្ឌឡើយ ជាពិសេសនៅតាមអង្គភាពនគរបាល។

(ខ) សម្របសម្រួលលទ្ធភាពមន្ត្រីផ្តល់ជំនួយផ្នែកច្បាប់ ដែលត្រូវបានចាត់តាំង ដើម្បីផ្តល់ជំនួយដល់ជនទាំងឡាយ ដែលត្រូវបានឃាត់ខ្លួននៅតាមអង្គភាពនគរបាល និងទីកន្លែងឃុំខ្លួនផ្សេងៗទៀត សម្រាប់គោលបំណងផ្តល់ជំនួយបែបនេះ។

(គ) ធានាឲ្យមានការធ្វើជាតំណាងតាមផ្លូវច្បាប់ នៅគ្រប់កិច្ចដំណើរការនីតិវិធីមុនពេលជំនុំជម្រះក្តី និងនៅពេលជំនុំជម្រះក្តី។

(ឃ) ឃ្លាំមើល និងអនុវត្តតាមពេលកំណត់ឃាត់ខ្លួននៅតាមបន្ទប់ឃាត់ខ្លួនរបស់អង្គភាពនគរបាល ឬមណ្ឌលឃុំខ្លួនផ្សេងៗទៀត ឧ. ដោយណែនាំអាជ្ញាធរតុលាការឲ្យពិនិត្យមើលចំនួនសំណុំរឿងជនជាប់ឃុំជាប្រចាំនៅតាមមណ្ឌលឃុំខ្លួន ដើម្បីធ្វើឲ្យប្រាកដថា ប្រជាពលរដ្ឋត្រូវបានឃុំខ្លួនស្របច្បាប់ ហើយធ្វើឲ្យប្រាកដថារឿងក្តីរបស់ពួកគេ ត្រូវបានដោះស្រាយទាន់ពេលវេលា និងល័ក្ខខ័ណ្ឌឃុំខ្លួនរបស់ពួកគេ បំពេញបានតាមបទដ្ឋានច្បាប់ពាក់ព័ន្ធ ក្នុងនោះរួមមាន បទដ្ឋានអន្តរជាតិផងដែរ។

(ង) ផ្តល់ដល់បុគ្គលគ្រប់រូបនៅពេលទទួលឲ្យចូលមកស្នាក់នៅក្នុងទីកន្លែងឃុំខ្លួន នូវព័ត៌មានអំពីសិទ្ធិរបស់ពួកគេ ដែលត្រូវបានចែងក្នុងច្បាប់វិធានផ្ទៃក្នុងរបស់ទីកន្លែងឃុំខ្លួន និងនៅដំណាក់កាលដំបូងនៃដំណើរការមុនពេលជំនុំជម្រះក្តី។ ព័ត៌មានបែបនេះគួរតែត្រូវបានផ្តល់ជូនតាមរបៀបមួយដែលស្របនឹងសេចក្តីត្រូវការរបស់ជនមិនចេះអក្សរ ជនជាតិភាគតិច

ជនពិការ និងកុមារ និងប្រើភាសា ដែលជនត្រូវការជំនួយផ្នែកច្បាប់អាចយល់បាន។ ព័ត៌មានដែលត្រូវផ្តល់ជូនកុមារ គួរតែត្រូវបានផ្តល់តាមរបៀបមួយ ដែលសមស្របតាមអាយុ និងភាពចាស់ទុំរបស់ពួកគេ។ ឯកសារព័ត៌មាននេះ គួរតែមានជំនួយជារូបភាព ឬវីដេអូ ដែលត្រូវបានដាក់តាំង អាចមើលឃើញបាន នៅតាមមណ្ឌលឃុំខ្លួននីមួយៗ។

(ច) ស្នើសុំគណៈមេធាវីឬសមាគមច្បាប់ និងស្ថាប័នដៃគូផ្សេងៗទៀត ដើម្បីរៀបចំបង្កើតបញ្ជីឈ្មោះមេធាវី និងអ្នកជំនួយការមេធាវី ដើម្បីគាំទ្រដល់ប្រព័ន្ធច្បាប់ដ៏ទូលំទូលាយមួយ សម្រាប់ជនទាំងឡាយដែលត្រូវបានឃុំខ្លួន ចាប់ខ្លួន សង្ស័យ ឬត្រូវបានចោទប្រកាន់ ឬក៏ត្រូវបានជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ជាពិសេសនៅតាមអង្គភាពនគរបាល។

(ឆ) ធានាថាជនគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មានពេលវេលា លទ្ធភាព និងការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុគ្រប់គ្រាន់ ក្នុងករណីដែលពួកគេមិនមានមធ្យោបាយគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការពារខ្លួន និងអាចពិគ្រោះយោបល់ជាមួយមេធាវីរបស់ពួកគេដោយសម្ងាត់ទាំងស្រុង។

## *គោលការណ៍ណែនាំទី៩៖ ជំនួយផ្នែកច្បាប់ក្នុងអំឡុងពេលដំណើរការនីតិវិធីតុលាការ*

៤៥. ដើម្បីធានាថា ជនគ្រប់រូបត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ដែលទោសដាក់ពន្ធនាគារ ឬទោសប្រហារជីវិត អាចត្រូវកំណត់ដោយតុលាការ មានសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ នៅគ្រប់ដំណើរការនីតិវិធីនៅតុលាការ ក្នុងនោះរួមមាន នៅអំឡុងពេលដំណើរការឧទ្ធរណ៍ និងដំណើរ

ការនីតិវិធីពាក់ព័ន្ធផ្សេងៗទៀត ទន្ទឹមនឹងនេះ រដ្ឋទាំងឡាយត្រូវដាក់ចេញនូវវិធានការនានាដូចតទៅដើម្បីៈ

(ក) ធានាថា គ្រប់ជនជាប់ចោទ យល់ដឹងពីរឿងក្តីប្រឆាំងនឹងខ្លួន និងផលវិបាកនៃការជំនុំជម្រះក្តី ដែលអាចកើតមានឡើង។

(ខ) ធានាថាគ្រប់ជនដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌមានពេលវេលា លទ្ធភាព ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុគ្រប់គ្រាន់ ក្នុងករណីដែលពួកគេមិនមានធនធានគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការពារខ្លួននិងអាចពិគ្រោះយោបល់ជាមួយមេធាវីរបស់ពួកគេដោយសម្ងាត់ទាំងស្រុង។

(គ) ផ្តល់នូវការធ្វើជាតំណាង នៅក្នុងដំណើរការនីតិវិធីតុលាការណាមួយ ដោយមេធាវីតាមការជ្រើសរើសរបស់ខ្លួន ក្នុងករណីចាំបាច់ ឬដោយមេធាវីដែលមានសមត្ថកិច្ចដែលត្រូវបានចាត់តាំងដោយតុលាការ ឬអាជ្ញាធរជំនួយផ្នែកច្បាប់ផ្សេងទៀត ដោយឥតបង់ថ្លៃ នៅពេលដែលជននោះមិនមានធនធានគ្រប់គ្រាន់សម្រាប់បង់ថ្លៃ និង/ឬក្នុងករណីដែលផលប្រយោជន៍ផ្នែកយុត្តិធម៌ តម្រូវឲ្យធ្វើដូច្នោះ។

(ឃ) ធានាថាអ្នកការពារក្តីរបស់ជនជាប់ចោទត្រូវមានវត្តមាននៅគ្រប់ដំណាក់កាលសំខាន់ៗនៃដំណើរការនីតិវិធី។ ដំណាក់កាលសំខាន់ៗ ជាដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីព្រហ្មទណ្ឌដែលការណែនាំរបស់មេធាវី មានភាពចាំបាច់ ដើម្បីធានាឲ្យបាននូវសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌សម្រាប់ជនជាប់ចោទ ឬដែលអវត្តមានអ្នកការពារក្តីអាចធ្វើឲ្យខូចខាតដល់ការត្រៀមរៀបចំ ឬការបង្ហាញនូវការការពារខ្លួន។

(ង) ស្នើសុំគណៈមេធាវី ឬសមាគមច្បាប់ និងស្ថាប័នជាដៃគូផ្សេងៗទៀត ឲ្យរៀបចំបង្កើតបញ្ជីឈ្មោះ និងមុខងាររបស់មេធាវី និងអ្នកជំនួយមេធាវី ដើម្បីគាំទ្រដល់ប្រព័ន្ធច្បាប់ដ៏ទូលំទូលាយមួយ សម្រាប់ជនទាំងឡាយ ដែលត្រូវបានឃុំ-ឃាត់ខ្លួន ចាប់ខ្លួន សង្ស័យ ឬចោទប្រកាន់ ឬជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ។ ការគាំទ្របែបនេះ អាចរួមបញ្ចូល ជាតួយ៉ាងការបង្ហាញខ្លួននៅចំពោះមុខតុលាការតាមថ្ងៃកំណត់ជាដើម។

(ច) បង្កលទ្ធភាពដល់អ្នកជំនួយមេធាវី និងនិស្សិតផ្នែកច្បាប់ ក្នុងការផ្តល់ជំនួយផ្នែកច្បាប់ តាមប្រភេទសមស្រប ដល់ជនជាប់ចោទនៅតាមតុលាការ ដោយអនុលោមតាមច្បាប់ជាតិ ឲ្យតែពួកគេស្ថិតនៅក្រោមការត្រួតពិនិត្យមើលរបស់មេធាវីជំនាញ។

(ឆ) ធានាថា ជនសង្ស័យដែលគ្មានតំណាង និងជនជាប់ចោទ យល់ដឹងពីសិទ្ធិរបស់ខ្លួនគេ។ នេះអាចរួមបញ្ចូល ប៉ុន្តែមិនកម្រិតត្រឹមការតម្រូវឲ្យចៅក្រម និងព្រះរាជអាជ្ញា ពន្យល់អំពីសិទ្ធិដល់ពួកគេជាភាសាច្បាស់លាស់ និងងាយយល់។

## *គោលការណ៍ណែនាំទី៦៖ ជំនួយផ្នែកច្បាប់នៅដំណាក់កាលក្រោយការជំនុំជម្រះក្តី*

៤៦. រដ្ឋទាំងឡាយត្រូវតែធានាថា ជនត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារ និងកុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាពរបស់ពួកគេ មានសិទ្ធិទទួលបានជំនួយផ្នែកច្បាប់។ ក្នុងករណីដែលគ្មានជំនួយផ្នែកច្បាប់ រដ្ឋទាំងឡាយត្រូវធានាថា ជនទាំងនេះ ត្រូវតែបានឃុំខ្លួននៅក្នុងពន្ធនាគារ ដោយអនុលោមតាមច្បាប់។

៤៧. សម្រាប់គោលបំណងនេះ រដ្ឋទាំងឡាយត្រូវតែដាក់ចេញនូវវិធានការនានាដើម្បី៖

(ក) ផ្តល់ដល់ជនគ្រប់រូបនៅពេលទទួលឲ្យចូលក្នុងពន្ធនាគារ និងក្នុងអំឡុងពេលឃុំខ្លួនពួកគេ នូវព័ត៌មានអំពីបទបញ្ជាផ្ទៃក្នុងពន្ធនាគារ និងសិទ្ធិរបស់ពួកគេតាមច្បាប់ ក្នុងនោះរួមមាន សិទ្ធិទទួលបានជំនួយផ្នែកច្បាប់ ការណែនាំ និងសេវាជំនួយផ្នែកច្បាប់ដោយសម្ងាត់ លទ្ធភាពសម្រាប់ពិនិត្យឡើងវិញបន្តទៀតលើរឿងក្តីរបស់ពួកគេ សិទ្ធិរបស់ពួកគេក្នុងអំឡុងពេលដំណើរការនីតិវិធីខាងវិន័យ និងនីតិវិធីសម្រាប់ដាក់ពាក្យបណ្តឹងនៅសាលាដំបូង បណ្តឹងឧទ្ធរណ៍ ការដោះលែងមុនកាលកំណត់ ការលើកលែងទោស ឬការបន្ធូរបន្ថយទោស។ ព័ត៌មានបែបនេះគួរតែត្រូវបានផ្តល់ជូនតាមរបៀបមួយ ដែលស្របនឹងសេចក្តីត្រូវការរបស់ជនមិនចេះអក្សរ ជនជាតិភាគតិច ជនពិការ និងកុមារ និងប្រើប្រាស់ភាសា ដែលជនត្រូវការជំនួយផ្នែកច្បាប់យល់ដឹងបាន។ ព័ត៌មានដែលត្រូវផ្តល់ជូនកុមារ គួរតែត្រូវបានផ្តល់តាមរបៀបមួយ ដែលសមស្របទៅនឹងអាយុ និងភាពចាស់ទុំរបស់ពួកគេ។ ឯកសារព័ត៌មាននេះ គួរតែមានរូបភាពសម្រាប់ជាជំនួយ ដែលត្រូវដាក់តាំងនៅក្នុងផ្នែកទាំងនោះនៃអគារពន្ធនាគារ ដែលអ្នកជាប់ពន្ធនាគារ អាចចេញចូលមើលឃើញបានច្បាស់ជាទៀងទាត់។

(ខ) លើកទឹកចិត្តដល់គណៈមេធាវី និងសមាគមច្បាប់ និងមន្ត្រីផ្តល់ជំនួយផ្នែកច្បាប់ផ្សេងៗទៀតឲ្យរៀបចំបញ្ជីឈ្មោះ និងមុខងាររបស់មេធាវី និងអ្នកជំនួយមេធាវីក្នុងករណីចាំបាច់ ដើម្បីចុះធ្វើទស្សនកិច្ចពិនិត្យមើលពន្ធនាគារ ដើម្បីផ្តល់ជំនួយ និងការណែនាំផ្នែកច្បាប់ដល់ជនត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារដោយឥតគិតថ្លៃ។

(គ) ធានាថា ជនត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារមានសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ សម្រាប់គោលបំណងដាក់បណ្តឹងឧទ្ធរណ៍ និងដាក់សំណើទាំងឡាយទាក់ទងនឹងប្រព្រឹត្តកម្មមិនគប្បីមកលើពួកគេនិងល័ក្ខខ័ណ្ឌនៃការឃុំខ្លួនក្នុងពន្ធនាគាររបស់ពួកគេ ក្នុងនោះរួមមាន នៅពេលប្រឈមមុខនឹងបទចោទប្រកាន់ខាងវិន័យធ្ងន់ធ្ងរ និងសម្រាប់សំណើសុំការលើកលែងទោស ជាពិសេស សម្រាប់អ្នកជាប់ពន្ធនាគារទាំងនោះដែលប្រឈមមុខនឹងទោសប្រហារជីវិត ក៏ដូចជាសម្រាប់ដាក់ពាក្យសុំដោះលែងដោយមានល័ក្ខខ័ណ្ឌ និងការធ្វើជាតំណាងនៅក្នុងសវនាការលើការដោះលែងដោយមានល័ក្ខខ័ណ្ឌមុនពេលកំណត់។

(ឃ) ផ្តល់ព័ត៌មានដល់អ្នកជាប់ពន្ធនាគារទាំងឡាយ ជាជនបរទេស អំពីលទ្ធភាពក្នុងការស្វែងរក ការផ្ទេរឲ្យទៅបំរើទោសក្នុងប្រទេសដើមរបស់ពួកគេ ក្នុងករណីដែលអាចធ្វើទៅបាន ដោយអាស្រ័យទៅលើការព្រមព្រៀងពីរដ្ឋដែលពាក់ព័ន្ធ។

## *គោលការណ៍ណែនាំទី៧៖ ជំនួយផ្នែកច្បាប់សម្រាប់ជនរងគ្រោះ*

៤៨. ដោយមិនប៉ះពាល់ដល់ ឬដោយស្របទៅនឹងសិទ្ធិរបស់ជនជាប់ចោទ និងដោយស្របទៅតាមច្បាប់ជាតិពាក់ព័ន្ធ រដ្ឋទាំងឡាយត្រូវតែចាត់វិធានការគ្រប់គ្រាន់ ក្នុងករណីចាំបាច់ ដើម្បីធានាថា៖

(ក) ការណែនាំ ជំនួយ ការថែទាំ លទ្ធភាព និងការគាំទ្រសមស្រប ត្រូវតែបានផ្តល់គ្រប់គ្រាន់ជូនដល់ជនរងគ្រោះដោយអំពើឧក្រិដ្ឋកម្មនៅគ្រប់ពេលដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ តាមរបៀបមួយដែលបង្ការភាពទទួលរងគ្រោះផ្ទួនៗ និងភាពទទួលរងគ្រោះដោយប្រយោល។[១៦]

(ខ) ជនរងគ្រោះជាកុមារទទួលសេវាជំនួយផ្នែកច្បាប់ដូចតាមលក្ខខណ្ឌតម្រូវដោយអនុលោមតាមគោលការណ៍ណែនាំទាំងឡាយស្តីពីយុត្តិធម៌ក្នុងបញ្ហាពាក់ព័ន្ធនឹងកុមាររងគ្រោះនិងសាក្សីជាកុមារដោយអំពើឧក្រិដ្ឋកម្ម។[១៧]

(គ) ជនរងគ្រោះ ទទួលការណែនាំផ្នែកច្បាប់លើទិដ្ឋភាពណាមួយ នៃការចូលរួមពាក់ព័ន្ធរបស់ពួកគេ នៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងនោះរួមមានលទ្ធភាពក្នុងការចាត់វិធានការរដ្ឋប្បវេណី ឬការទាមទារសំណងជំងឺចិត្តនៅក្នុងដំណើរការនីតិវិធីផ្លូវច្បាប់ដោយឡែក ដែលដំណើរការនីតិវិធីមួយណាក៏ដោយ ឲ្យតែស្របទៅនឹងច្បាប់ជាតិពាក់ព័ន្ធ។

(ឃ) ជនរងគ្រោះត្រូវបានផ្តល់ជាបន្ទាន់ដោយនគរបាល និងអ្នកឆ្លើយតបជួរមុខផ្សេងៗទៀត (ពោលគឺមន្ត្រីសុខាភិបាល មន្ត្រីសង្គមកិច្ច និងមន្ត្រីសុខុមាលភាពកុមារ) នូវសិទ្ធិទទួលបានព័ត៌មានរបស់ពួកគេ និងសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ សេវាជំនួយផ្នែកច្បាប់ និងកិច្ចការពារ ព្រមទាំងវិធីសំរាប់អនុវត្តសិទ្ធិទាំងនេះ។

---

[១៦] ″ភាពទទួលរងគ្រោះផ្ទួនៗ″ និង″ភាពទទួលរងគ្រោះដោយប្រយោល ″ ត្រូវបានស្វែងយល់ដូចដែលបានឲ្យនិយមន័យនៅក្នុងកថាខ័ណ្ឌ១.២ និង១.៣ នៃឧបសម្ព័ន្ធដែលភ្ជាប់ទៅនឹងអនុសាសន៍ Rec(2006) ៨ របស់គណៈកម្មាធិការរដ្ឋមន្ត្រីនៃក្រុមប្រឹក្សាអឺរ៉ុប ជូនចំពោះរដ្ឋជាសមាជិកស្តីពីជំនួយសម្រាប់ជនរងគ្រោះដោយអំពើឧក្រិដ្ឋកម្ម។

[១៧] ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ 2005/20 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច។

(ង) ទស្សនៈ និងកង្វល់របស់ជនរងគ្រោះ ត្រូវបានបង្ហាញជូន និងពិចារណានៅតាមដំណាក់កាលសមស្របនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងករណីដែលផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ ត្រូវទទួលរងផលប៉ះពាល់ ឬក្នុងករណីដែលផលប្រយោជន៍ផ្នែកយុត្តិធម៌តម្រូវឲ្យធ្វើដូច្នោះ។

(ច) ទីភ្នាក់ងារផ្នែកសេវាជនរងគ្រោះ និងអង្គការមិនមែនរដ្ឋាភិបាល អាចផ្តល់ជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ។

(ឆ) យន្តការ និងនីតិវិធី ត្រូវរៀបចំបង្កើតឡើងដើម្បីធានាឲ្យមានសហប្រតិបត្តិការជិតស្និទ្ធ និងប្រព័ន្ធបញ្ជូនសមស្រប រវាងមន្ត្រីជំនួយផ្នែកច្បាប់ និងអ្នកប្រកបវិជ្ជាជីវៈច្បាប់ផ្សេងៗទៀត (ពោលគឺមន្ត្រីសុខាភិបាល មន្ត្រីសង្គមកិច្ច និងមន្ត្រីសុខុមាលភាពកុមារ) ដើម្បីទទួលបានការយល់ដឹងដ៏ទូលំទូលាយអំពីជនរងគ្រោះ ក៏ដូចជាការវាយតម្លៃទៅលើសេចក្តីត្រូវការ និងស្ថានភាពផ្នែកច្បាប់ ចិត្តសាស្ត្រ សង្គមកិច្ច សតិបញ្ញា រូបកាយ និងអារម្មណ៍របស់ពួកគេ។

## *គោលការណ៍ណែនាំទី៨៖ ជំនួយផ្នែកច្បាប់សម្រាប់សាក្សី*

៤៩. រដ្ឋទាំងឡាយ ត្រូវតែចាត់វិធានការគ្រប់គ្រាន់ក្នុងករណីចាំបាច់ ដើម្បីធានាថា៖

(ក) អាជ្ញាធរពាក់ព័ន្ធ ត្រូវប្រាប់សាក្សីឲ្យបានដឹងជាបន្ទាន់ អំពីសិទ្ធិទទួលបានព័ត៌មាន សិទ្ធិទទួលបានជំនួយ និងទទួលបានកិច្ចការពាររបស់ពួកគេ និងវិធីប្រើប្រាស់សិទ្ធិបែបនេះ។

(ខ) ការណែនាំ ជំនួយ លទ្ធភាព ការថែទាំ និងការគាំទ្រសមស្រប ត្រូវបានផ្តល់ជូនដល់សាក្សី ពីអំពើឧក្រិដ្ឋកម្ម នៅគ្រប់ដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។

(គ) សាក្សីជាកុមារ ទទួលសេវាជំនួយផ្នែកច្បាប់ តាមលក្ខខណ្ឌតម្រូវ ដោយអនុលោមតាមគោលការណ៍ណែនាំទាំងឡាយ ស្តីពីយុត្តិធម៌ក្នុងបញ្ហាពាក់ព័ន្ធនឹងកុមាររងគ្រោះ និងសាក្សីជាកុមារ ពីអំពើឧក្រិដ្ឋកម្ម។

(ឃ) ចម្លើយ ឬសក្ខីកម្មទាំងអស់ ដែលត្រូវបានផ្តល់ដោយសាក្សី នៅគ្រប់ដំណាក់កាលនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ត្រូវតែបានបកប្រែផ្ទាល់មាត់ និងបកប្រែជាឯកសារយ៉ាងត្រឹមត្រូវ។

៥០. ក្នុងករណីចាំបាច់ រដ្ឋទាំងឡាយត្រូវតែផ្តល់ជំនួយផ្នែកច្បាប់ដល់សាក្សី។

៥១. ស្ថានភាពដែលវាអាចសមស្របដើម្បីផ្តល់ជំនួយផ្នែកច្បាប់ដល់សាក្សី រួមបញ្ចូល ប៉ុន្តែមិនកម្រិតត្រឹមស្ថានភាពទាំងឡាយដែល៖

(ក) សាក្សីប្រឈមនឹងការឆ្លើយដាក់បន្ទុកទៅលើខ្លួនឯង។

(ខ) មានគ្រោះថ្នាក់ចំពោះសុវត្ថិភាព និងសុខុមាលភាពរបស់សាក្សី ដែលកើតឡើងដោយសារឋានៈបែបនេះរបស់គេនៅក្នុងរឿងក្តី។

(គ) សាក្សីជាជនងាយរងគ្រោះពិសេស រួមទាំងដោយសារតែពួកគេមានតម្រូវការពិសេស។

## *គោលការណ៍ណែនាំទី៩៖ ការអនុវត្តសិទ្ធិទទួលបានជំនួយផ្នែកច្បាប់របស់ស្ត្រី*

៥២. រដ្ឋទាំងឡាយត្រូវតែចាត់វិធានការដែលអាចអនុវត្តបាន និងសមស្រប ដើម្បីធានានូវសិទ្ធិទទួលបានជំនួយផ្នែកច្បាប់សម្រាប់ស្ត្រីក្នុងនោះរួមមាន៖

(ក) ដាក់ចេញនូវគោលនយោបាយយ៉ាងសកម្ម ដោយដាក់បញ្ចូលទស្សនវិស័យយេនឌ័រទៅក្នុងគោលនយោបាយ ច្បាប់ នីតិវិធី កម្មវិធី និងការអនុវត្តទាំងអស់ ដែលទាក់ទងនឹងជំនួយផ្នែកច្បាប់ ដើម្បីធានាសមភាពយេនឌ័រ និងសិទ្ធិទទួលបានយុត្តិធម៌យ៉ាងត្រឹមត្រូវ និងស្មើភាពគ្នា។

(ខ) ចាត់វិធានការយ៉ាងសកម្មដើម្បីធានាថា ក្នុងករណីដែលអាចធ្វើទៅបាន ត្រូវមានមេធាវីជាស្ត្រីដើម្បីធ្វើជាតំណាងឲ្យចុងចោទ ជនជាប់ចោទ និងជនរងគ្រោះជាស្ត្រី។

(គ) ផ្តល់ជំនួយផ្នែកច្បាប់ ការណែនាំ និងសេវាគាំទ្រពីតុលាការ នៅគ្រប់ដំណើរការនីតិវិធីផ្លូវច្បាប់ដល់ស្ត្រីរងគ្រោះដោយអំពើហិង្សា ដើម្បីធានាឲ្យបាននូវសិទ្ធិទទួលបានយុត្តិធម៌ និងចៀសវាងភាពទទួលរងគ្រោះដោយប្រយោល និងសេវាបែបនេះផ្សេងទៀត ដែលអាចរួមបញ្ចូលនូវការបកប្រែឯកសារច្បាប់ ក្នុងករណីត្រូវបានស្នើសុំ ឬតាមលក្ខខ័ណ្ឌតម្រូវ។

## *គោលការណ៍ណែនាំទី១០៖ វិធានការពិសេសសម្រាប់កុមារ*

៥៣. រដ្ឋទាំងឡាយត្រូវតែធានាឲ្យមានវិធានការពិសេសសម្រាប់កុមារដើម្បីលើកកម្ពស់សិទ្ធិប្រកបដោយប្រសិទ្ធភាពរបស់កុមារ ក្នុងការទទួលបានយុត្តិ

ធម៌ និងដើម្បីបង្ការ-ទប់ស្កាត់ការធ្វើឲ្យមានស្លាកស្នាមទុយ៌ស និងឥទ្ធិពលមិនល្អផ្សេងៗទៀត ដោយសារតែពួកគេចូលរួមពាក់ព័ន្ធក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងនោះរួមមាន៖

(ក) ធានាឲ្យកុមារមានសិទ្ធិទទួលបានអ្នកការពារក្ដីដែលត្រូវបានចាត់តាំងដើម្បីធ្វើជាតំណាងឲ្យកុមារ ក្នុងនាមកុមារផ្ទាល់នៅក្នុងដំណើរការនីតិវិធី ក្នុងករណីមាន ឬអាចមានទំនាស់ផលប្រយោជន៍រវាងកុមារ និងមាតាបិតារបស់គេ ឬភាគីផ្សេងទៀតដែលពាក់ព័ន្ធ។

(ខ) ជួយកុមារដែលត្រូវបានឃុំខ្លួន ចាប់ខ្លួន សង្ស័យ ឬត្រូវបានចោទប្រកាន់ ឬក៏ត្រូវបានចោទពីបទល្មើសព្រហ្មទណ្ឌ ឲ្យមានលទ្ធភាពប្រាស្រ័យទាក់ទងជាមួយនឹងមាតាបិតា ឬអាណាព្យាបាលរបស់ពួកគេភ្លាមៗ និងហាមឃាត់ ការធ្វើសម្ភាសជាមួយកុមារដោយគ្មានវត្តមានមេធាវីរបស់គេ ឬមន្ត្រីផ្ដល់ជំនួយផ្នែកច្បាប់ផ្សេងៗទៀត និងមាតា ឬបិតា ឬ អាណាព្យាបាលបើមាន ដោយគិតគូរពីឧត្ដមប្រយោជន៍សម្រាប់កុមារ។

(គ) ធានាឲ្យកុមារមានសិទ្ធិឲ្យគេកំណត់បញ្ហាដោយមានវត្តមានមាតាបិតា ឬអាណាព្យាបាលតាមផ្លូវច្បាប់របស់កុមារ លើកលែងតែវាមិនត្រូវបានចាត់ទុកថាជាឧត្ដមប្រយោជន៍សម្រាប់កុមារ។

(ឃ) ធានាថាកុមារអាចពិគ្រោះយោបល់ដោយសេរី និងដោយសម្ងាត់ទាំងស្រុងជាមួយនឹងមាតាបិតា និង/ឬអាណាព្យាបាល និងតំណាងតាមផ្លូវច្បាប់។

(ង) ផ្ដល់ព័ត៌មានស្ដីពីសិទ្ធិស្របច្បាប់ តាមរបៀបមួយដែលសមស្រប ទៅនឹងអាយុ និងភាពចាស់ទុំរបស់កុមារ ជាភាសាដែលកុមារអាចយល់ដឹងបាន និងតាមរបៀបមួយដែលផ្ដោតទៅលើយេនឌ័រ និងវប្បធម៌។ ការផ្ដល់ព័ត៌មានដល់មាតាបិតា អាណាព្យាបាល ឬអ្នកផ្ដល់ការថែទាំ គួរតែធ្វើបន្ថែមទៅលើការផ្ដល់ព័ត៌មានដល់កុមារ និងមិនមែនជាជម្រើសផ្សេងពីនេះទេ។

(ច) ក្នុងករណីសមស្រប លើកកំពស់ការបង្វែពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌផ្លូវការ និងធានាថាកុមារមានសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ នៅគ្រប់ដំណាក់កាលនៃដំណើរការ ដែលត្រូវអនុវត្តការបង្វែ។

(ឆ) ក្នុងករណីសមស្រប លើកទឹកចិត្តដល់ការប្រើប្រាស់វិធានការ និងទណ្ឌកម្មដទៃទៀត ជាការជំនួសឲ្យការដកហូតសិទ្ធិសេរីភាព និងធានាថាកុមារមានសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ ដើម្បីឲ្យការដកហូតសិទ្ធិសេរីភាព ជាវិធានការចុងក្រោយបំផុត ហើយនឹងសំរាប់រយៈពេលសមស្របយ៉ាងខ្លីបំផុត។

(ជ) រៀបចំបង្កើតឡើងនូវវិធានការដើម្បីធានាថា ដំណើរការនីតិវិធីតាមផ្លូវតុលាការ និងរដ្ឋបាល ត្រូវបានអនុវត្តក្នុងបរិយាកាស និងតាមរបៀបមួយ ដែលអនុញ្ញាតឲ្យកុមារត្រូវបានគេស្ដាប់យកចម្លើយដោយផ្ទាល់ក៏បាន ឬតាមរយៈតំណាង ឬក៏តាមរយៈស្ថាប័នសមស្របមួយ តាមរបៀបមួយដែលស្របទៅនឹងវិធាននីតិវិធីនៃច្បាប់ជាតិក៏បាន។ ដោយពិចារណាទៅលើអាយុ និងភាពចាស់ទុំរបស់កុមារ ក៏អាចតម្រូវឲ្យមានការកែប្រែទម្លាប់អនុវត្ត និងនីតិវិធីទាំងឡាយតាមផ្លូវតុលាការ និងរដ្ឋបាលផងដែរ។

៥៤. ជីវិតឯកជន និងទិន្នន័យជីវៈប្រវត្តិផ្ទាល់ខ្លួនរបស់កុមារ ដែលត្រូវ ឬបានពាក់ព័ន្ធ នៅក្នុងដំណើរការនីតិវិធីតាមផ្លូវតុលាការ ឬមិនមែនតាមផ្លូវតុលាការ និងអន្តរាគមន៍ផ្សេងៗទៀត ត្រូវតែទទួលបានការការពារនៅគ្រប់ដំណាក់កាល ហើយការការពារបែបនេះត្រូវតែធានាដោយច្បាប់។ ជាទូទៅ ប្រការនេះមានន័យថា គ្មានព័ត៌មាន ឬទិន្នន័យជីវៈប្រវត្តិផ្ទាល់ខ្លួនណាមួយអាចត្រូវបានបញ្ចេញ ឬផ្សព្វផ្សាយឲ្យគេដឹងឡើយ ជាពិសេសតាមប្រព័ន្ធផ្សព្វផ្សាយដែលអាចបញ្ចេញឲ្យដឹង ឬអាចបញ្ចេញឲ្យដឹងដោយប្រយោលនូវអត្តសញ្ញាណរបស់កុមារ ក្នុងនោះរួមមានរូបរបស់កុមារ សេចក្តីពណ៌នាពិស្តារអំពីកុមារ ឬក្រុមគ្រួសាររបស់កុមារ ឈ្មោះ ឬអាសយដ្ឋានរបស់សមាជិកគ្រួសារកុមារ និងកំណត់ត្រាសោតទស្សន៍ និងវីដេអូ។

## *គោលការណ៍ណែនាំទី១១៖ ប្រព័ន្ធជំនួយផ្នែកច្បាប់ទូទាំងប្រទេស*

៥៥. ដើម្បីលើកទឹកចិត្តដល់ដំណើរការប្រព័ន្ធជំនួយផ្នែកច្បាប់ទូទាំងប្រទេសតាមករណីសមស្រប រដ្ឋទាំងឡាយ ត្រូវតែចាត់វិធានការដូចតទៅ ដើម្បី៖

(ក) ធានា និងលើកកម្ពស់ការផ្តល់ជំនួយផ្នែកច្បាប់ ប្រកបដោយប្រសិទ្ធភាព នៅគ្រប់ដំណាក់កាលនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ដល់ជនទាំងឡាយដែលត្រូវបានឃុំខ្លួន ចាប់ខ្លួន ឬត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារ សង្ស័យ ឬត្រូវបានចោទប្រកាន់ ឬក៏ត្រូវបានចោទពីបទល្មើសព្រហ្មទណ្ឌ និងដល់ជនរងគ្រោះដោយអំពើឧក្រិដ្ឋកម្ម។

(ខ) ផ្តល់ជំនួយផ្នែកច្បាប់ដល់ជនទាំងឡាយដែលត្រូវបានចាប់ខ្លួន ឬត្រូវបានឃុំខ្លួនដោយខុសច្បាប់ ឬដែលបានទទួលសាលក្រមស្ថាពររបស់តុលាការ ជាលទ្ធផលនៃយុត្តិនិសេធ ក្នុងគោលបំណងប្រតិបត្តិនូវសិទ្ធិរបស់ពួកគេ ក្នុងការទទួលបានការជំនុំជម្រះក្តីឡើងវិញ ការជួសជុលសំណងក្នុងនោះរួមមាន សំណងជំងឺចិត្ត ការស្តារនីតិសម្បទាឡើងវិញ និងកិច្ចធានាការពារមិនឲ្យកើតឡើងជាថ្មី។

(គ) លើកកម្ពស់ការសម្របសម្រួលរវាងទីភ្នាក់ងារយុត្តិធម៌ និងមន្ត្រីជំនាញផ្សេងៗទៀត ដូចជាមន្ត្រីសុខាភិបាល សេវាសង្គមកិច្ច និងបុគ្គលិកគាំទ្រជនរងគ្រោះ ដើម្បីបង្កើនឲ្យបានខ្ពស់ជាអតិបរមានូវប្រសិទ្ធភាពនៃប្រព័ន្ធ ជំនួយផ្នែកច្បាប់ ដោយមិនប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ។

(ឃ) រៀបចំបង្កើតភាពជាដៃគូជាមួយនឹងគណៈមេធាវី ឬសមាគមច្បាប់ ដើម្បីធានាឲ្យមានការផ្តល់ជំនួយផ្នែកច្បាប់ នៅគ្រប់ដំណាក់កាលនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។

(ង) ជួយអ្នកជំនួយមេធាវី ឲ្យមានលទ្ធភាពផ្តល់នូវជំនួយផ្នែកច្បាប់តាមទម្រង់ទាំងនោះ ដែលត្រូវបានអនុញ្ញាតតាមច្បាប់ជាតិ ឬទម្លាប់អនុវត្តដល់ជនទាំងឡាយដែលត្រូវបានចាប់ខ្លួន ឃុំខ្លួន សង្ស័យ ឬត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ជាពិសេស នៅអង្គភាពនគរបាល ឬមណ្ឌលឃុំខ្លួនផ្សេងៗទៀត។

(ច) លើកកម្ពស់ការផ្តល់ជំនួយផ្នែកច្បាប់សមស្រប សម្រាប់គោលបំណងបង្ការ-ទប់ស្កាត់អំពើឧក្រិដ្ឋកម្ម។

៥៦. រដ្ឋទាំងឡាយក៏ត្រូវចាត់វិធានការដូចខាងក្រោមផងដែរដើម្បី៖

(ក) លើកទឹកចិត្តដល់សមាគមច្បាប់ និងគណៈមេធាវី ដើម្បីគាំទ្រដល់ការផ្តល់ជំនួយផ្នែកច្បាប់ ដោយផ្តល់សេវាច្រើនផ្នែក ក្នុងនោះរួមមានសេវាដែលឥតគិតថ្លៃ ដោយអនុលោមតាមក្រមសីលធម៌ និងបេសកកម្មចាំបាច់ខាងវិជ្ជាជីវៈច្បាប់របស់ស្ថាប័នទាំងនេះ។

(ខ) កំណត់អំពីគ្រឿងលើកទឹកចិត្តសម្រាប់មេធាវី ដើម្បីចុះធ្វើការនៅតាមតំបន់ ដែលមានវិបត្តិខាងសេដ្ឋកិច្ច និងសង្គមកិច្ច (ឧទាហរណ៍ៈ ការលើកលែងពន្ធ ការផ្តល់អាហារូបករណ៍ និងប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ ព្រមទាំងប្រាក់សម្រាប់ការធ្វើដំណើរ)។

(គ) លើកទឹកចិត្តដល់មេធាវីឲ្យរៀបចំដំណើរទស្សនកិច្ចជាទៀងទាត់ជុំវិញប្រទេសដើម្បីផ្តល់ជំនួយផ្នែកច្បាប់ដល់អ្នកដែលត្រូវការសេវាបែបនេះ។

៥៧. ក្នុងការរៀបចំគម្រោងជំនួយផ្នែកច្បាប់ទូទាំងប្រទេសរបស់ខ្លួន រដ្ឋទាំងឡាយ ត្រូវពិចារណាទៅលើសេចក្តីត្រូវការរបស់ក្រុមមនុស្សជាក់លាក់ ក្នុងនោះរួមមានប៉ុន្តែមិនកម្រិតត្រឹមមនុស្សចាស់ ជនជាតិភាគតិច ជនពិការមនុស្សវិកលចរិត អ្នកផ្ទុកមេរោគអេដស៍ និងជំងឺឆ្លងធ្ងន់ធ្ងរផ្សេងៗទៀត អ្នកប្រើប្រាស់គ្រឿងញៀន ជនជាតិដើមភាគតិច និងជនអម្បូរដើម អ្នកសុំសិទ្ធិជ្រកកោន ជនគ្មានសញ្ជាតិ ជនបរទេស ជនភៀសខ្លួន និងជនចំណាកស្រុកនៅក្នុងប្រទេស ដោយអនុលោមតាមគោលការណ៍ណែនាំទី៩ និងទី១០។

៥៨. រដ្ឋទាំងឡាយត្រូវតែចាត់វិធានការសមស្រប ដើម្បីរៀបចំបង្កើតប្រព័ន្ធជំនួយផ្នែកច្បាប់ ដែលមានលក្ខណៈកុមារមេត្រី[១៨] និងផ្តោតលើកុមារ

[១៨] "ជំនួយផ្នែកច្បាប់កុមារមេត្រី" គឺជាការផ្តល់សេវាជំនួយផ្នែកច្បាប់ដល់កុមារ នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ រដ្ឋប្បវេណី និងរដ្ឋបាលដែលអាចមានលទ្ធភាពទទួលបានសមស្របតាមអាយុ ជាពហុវិស័យ និងមានប្រសិទ្ធភាព និងដែលអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការផ្នែកច្បាប់ និងសង្គមកិច្ចច្រើនផ្នែក ដែលត្រូវបានប្រឈមមុខដោយកុមារ និងយុវជន។ ជំនួយផ្នែកច្បាប់កុមារមេត្រី ត្រូវបានផ្តល់ដោយមេធាវី និងអ្នកដែលមិនមែនជាមេធាវី ដែលត្រូវបានបណ្តុះបណ្តាលក្នុងវិស័យច្បាប់ស្តីពីកុមារ និងការចម្រើនលូតលាស់របស់កុមារ និងយុវជន ហើយដែលអាចធ្វើការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមួយនឹងកុមារ និងអ្នកថែទាំកុមារ។

ដោយពិចារណាទៅលើសមត្ថភាពដែលកំពុងមានការវិវត្តរបស់កុមារ និង សេចក្តីត្រូវការ ធ្វើឲ្យមានតុល្យភាពសមស្របរវាងឧត្តមប្រយោជន៍សម្រាប់ កុមារ និងសិទ្ធិស្នើសុំឲ្យគេស្តាប់យកចម្លើយរបស់កុមារ នៅក្នុងដំណើរការ នីតិវិធីតាមផ្លូវតុលាការ ក្នុងនោះរួមមានៈ

(ក) ក្នុងករណីដែលអាចធ្វើទៅបាន រៀបចំបង្កើតយន្តការឯករាជ្យ ទាំងឡាយ ដើម្បីគាំទ្រដល់ជំនួយផ្នែកច្បាប់ជាលក្ខណៈឯកទេស សម្រាប់ កុមារ និងគាំទ្រដល់ការធ្វើសមាហរណកម្មជំនួយផ្នែកច្បាប់កុមារមេត្រី ទៅ ក្នុងយន្តការទូទៅ ហើយដែលមិនមែនជាលក្ខណៈឯកទេស។

(ខ) អនុម័តច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានក្រោមច្បាប់ ទាក់ទងនឹងជំនួយផ្នែកច្បាប់ដែលគិតគូរយ៉ាងច្បាស់លាស់នូវសិទ្ធិ និងសេច ក្តីត្រូវការសម្រាប់ការចម្រើនលូតលាស់ពិសេសរបស់កុមារ ក្នុងនោះរួមមាន សិទ្ធិទទួលបានសេវាជំនួយផ្នែកច្បាប់ ឬជំនួយសមស្របផ្សេងៗទៀត ដើម្បី ត្រៀមរៀបចំបង្ហាញនូវមធ្យោបាយការពារខ្លួនរបស់គេ សិទ្ធិស្នើសុំឲ្យគេ ស្តាប់យកចម្លើយនៅគ្រប់ដំណើរការនីតិវិធីតាមផ្លូវតុលាការ ដែលប៉ះពាល់ ដល់រូបគេ នីតិវិធី បទដ្ឋានសម្រាប់កំណត់នូវឧត្តមប្រយោជន៍របស់កុមារ សិទ្ធិជីវិតឯកជន និងការការពារទិន្នន័យជីវៈប្រវត្តិផ្ទាល់ខ្លួន និងសិទ្ធិត្រូវ បានពិចារណាសំរាប់ការបង្វែរ។

(គ) រៀបចំបង្កើតបទដ្ឋានសេវាជំនួយផ្នែកច្បាប់ជាលក្ខណៈកុមារមេត្រី និងក្រមសីលធម៌វិជ្ជាជីវៈ។ ក្នុងករណីចាំបាច់ មន្ត្រីផ្តល់ជំនួយផ្នែកច្បាប់ ដែលធ្វើការងារជាមួយ និងសំរាប់កុមារ ត្រូវទទួលការត្រួតពិនិត្យវាយតម្លៃពី លក្ខណៈសម្បត្តិជាទៀងទាត់ ដើម្បីធានានូវសមត្ថភាពរបស់ពួកគេឲ្យស័ក្ត សមសម្រាប់ធ្វើការងារជាមួយកុមារ។

(ឃ) លើកកម្ពស់កម្មវិធីបណ្តុះបណ្តាលជំនួយផ្នែកច្បាប់ជាលក្ខណៈបទដ្ឋាន។ មន្ត្រីផ្តល់ជំនួយផ្នែកច្បាប់ដែលធ្វើជាតំណាងឲ្យកុមារ ត្រូវទទួលការបណ្តុះបណ្តាលអំពីសិទ្ធិកុមារ និងបញ្ហាពាក់ព័ន្ធ ហើយនឹងមានចំណេះដឹងអំពីសិទ្ធិ និងបញ្ហាពាក់ព័ន្ធទាំងនេះ ដោយទទួលកាបណ្តុះបណ្តាលជាបន្ត និងមានលក្ខណៈស៊ីជម្រៅ និងមានសមត្ថភាពអាចធ្វើការប្រាស្រ័យទាក់ទងជាមួយកុមារបានទៅតាមកម្រិតយល់ដឹងរបស់ពួកគេ។ មន្ត្រីជំនួយផ្នែកច្បាប់ទាំងអស់ ដែលធ្វើការជាមួយនឹង និងសំរាប់កុមារ ត្រូវទទួលការបណ្តុះបណ្តាលជាលក្ខណៈអន្តរវិស័យជាមូលដ្ឋាន ស្តីពីសិទ្ធិ និងសេចក្តីត្រូវការរបស់កុមារដែលមានអាយុខុសៗគ្នា និងដំណើរការនីតិវិធីដែលត្រូវកែសម្រួលទៅតាមតម្រូវការរបស់ពួកគេ និងការបណ្តុះបណ្តាលអំពីទិដ្ឋភាពចិត្តសាស្ត្រ និងទិដ្ឋភាពផ្សេងៗទៀត ទាក់ទងនឹងការចម្រើនលូតលាស់របស់កុមារ ដោយមានការយកចិត្តទុកដាក់ពិសេសចំពោះក្មេងស្រី និងកុមារដែលជាសមាជិកនៃក្រុមជនជាតិភាគតិច ឬក្រុមមនុស្សដែលជាជនជាតិដើមភាគតិច ហើយនឹងវិធានការនានាដែលមានស្រាប់ សម្រាប់លើកកម្ពស់មធ្យោបាយការពារខ្លួនរបស់កុមារទំនាស់នឹងច្បាប់។

(ង) រៀបចំបង្កើតយន្តការ និងនីតិវិធីទាំងឡាយដើម្បីធានាឲ្យមានសហប្រតិបត្តិការជិតស្និទ្ធ និងប្រព័ន្ធបញ្ជូនសមស្រប រវាងមន្ត្រីផ្តល់ជំនួយផ្នែកច្បាប់ និងមន្ត្រីជំនាញផ្សេងៗគ្នា ដើម្បីឲ្យមានការស្វែងយល់ដ៏ទូលំទូលាយអំពីកុមារ ក៏ដូចជាការវាយតម្លៃទៅលើសេចក្តីត្រូវការ និងស្ថានភាពផ្នែកច្បាប់ ចិត្តសាស្ត្រ សង្គមកិច្ច សតិបញ្ញា រូបកាយ និងអារម្មណ៍របស់ពួកគេ។

៥៩. ដើម្បីធានាឲ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគម្រោងជំនួយផ្នែកច្បាប់ទូទាំងប្រទេស រដ្ឋទាំងឡាយ ត្រូវពិចារណាលើការរៀបចំបង្កើតស្ថាប័ន ឬអាជ្ញាធរជំនួយផ្នែកច្បាប់ ដើម្បីផ្តល់ គ្រប់គ្រង សម្របសម្រួល និងពិនិត្យតាមដានមើលសេវាជំនួយផ្នែកច្បាប់។ ស្ថាប័នបែបនេះត្រូវតែ៖

(ក) មិនត្រូវស្ថិតក្រោមការជ្រៀតជ្រែកផ្នែកនយោបាយ ឬតុលាការ ដែលមិនត្រឹមត្រូវ មានលក្ខណៈឯករាជ្យពីរដ្ឋាភិបាលក្នុងការធ្វើសេចក្តីសម្រេច ពាក់ព័ន្ធនឹងជំនួយផ្នែកច្បាប់ និងមិនស្ថិតក្រោមការបង្គាប់បញ្ជា ការត្រួតត្រា ឬការបំភិតបំភ័យផ្នែកហិរញ្ញវត្ថុពីបុគ្គល ឬអាជ្ញាធរណាមួយឡើយ ក្នុងការបំពេញមុខងាររបស់ខ្លួន ដោយមិនគិតពីរចនាសម្ព័ន្ធរដ្ឋបាលរបស់ខ្លួន។

(ខ) មានអំណាចចាំបាច់ដើម្បីផ្តល់ជំនួយផ្នែកច្បាប់ ក្នុងនោះរួមមាន ប៉ុន្តែមិនកម្រិតត្រឹមការតែងតាំងបុគ្គលិក ការចាត់តាំងសេវាជំនួយផ្នែកច្បាប់ ដល់បុគ្គលនានា ការកំណត់អំពីលក្ខណៈវិនិច្ឆ័យ និងការទទួលស្គាល់ជាផ្លូវការចំពោះមន្ត្រីផ្តល់ជំនួយផ្នែកច្បាប់ ក្នុងនោះរួមមាន តម្រូវការផ្នែកបណ្តុះបណ្តាល ការត្រួតពិនិត្យមើលមន្ត្រីផ្តល់ជំនួយផ្នែកច្បាប់ និងការរៀបចំបង្កើតស្ថាប័នឯករាជ្យទាំងឡាយ ដើម្បីដោះស្រាយបណ្តឹងប្រឆាំងនឹងមន្ត្រីទាំងនោះ ការវាយតម្លៃលើសេចក្តីត្រូវការជំនួយផ្នែកច្បាប់ទូទាំងប្រទេស និងអំណាចបង្កើតថវិការបស់ខ្លួនផ្ទាល់។

(គ) ដោយពិគ្រោះយោបល់ជាមួយនឹងមន្ត្រីពាក់ព័ន្ធសំខាន់ៗ ក្នុងវិស័យយុត្តិធម៌ និងអង្គការសង្គមស៊ីវិល ត្រូវបង្កើតយុទ្ធសាស្ត្ររយៈពេលវែង ដែលណែនាំអំពីការវិវត្ត និងនិរន្តរភាពនៃជំនួយផ្នែកច្បាប់។

(ឃ) ត្រូវរាយការណ៍ជាទៀងទាត់ទៅអាជ្ញាធរដែលទទួលខុសត្រូវ។

## *គោលការណ៍ណែនាំទី១២៖ ការផ្តល់មូលនិធិដល់ប្រព័ន្ធជំនួយផ្នែកច្បាប់ទូទាំងប្រទេស*

៦០. ដោយទទួលស្គាល់ថា ផលប្រយោជន៍នៃសេវាជំនួយផ្នែកច្បាប់ រួមបញ្ចូលផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ និងការសន្សំសំចៃថវិកានៅគ្រប់ពេលដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងករណីសមស្រប រដ្ឋទាំងឡាយត្រូវផ្តល់ថវិកាគ្រប់គ្រាន់ និងជាក់លាក់សម្រាប់សេវាជំនួយផ្នែកច្បាប់ ដែលសមស្របទៅនឹងសេចក្តីត្រូវការរបស់ខ្លួន ក្នុងនោះរួមមានតាមរយៈការផ្តល់យន្តការមូលនិធិទាំងឡាយដែលឯករាជ្យ និងមាននិរន្តរភាពសម្រាប់ប្រព័ន្ធជំនួយផ្នែកច្បាប់ថ្នាក់ជាតិ។

៦១. ដើម្បីសម្រេចគោលដៅនេះ រដ្ឋទាំងឡាយអាចចាត់វិធានការដូចតទៅ៖

(ក) រៀបចំបង្កើតមូលនិធិជំនួយផ្នែកច្បាប់ ដើម្បីផ្តល់ថវិកាដល់គម្រោងជំនួយផ្នែកច្បាប់ ក្នុងនោះរួមមាន គម្រោងអ្នកការពារក្តីក្នុងវិស័យសាធារណៈ ដើម្បីគាំទ្រដល់ការផ្តល់ជំនួយផ្នែកច្បាប់ពីសមាគមច្បាប់ ឬគណៈមេធាវី ដើម្បីគាំទ្រដល់ការិយាល័យពិគ្រោះច្បាប់នៅសកលវិទ្យាល័យ និងដើម្បីធានាអង្គការមិនមែនរដ្ឋាភិបាល និងអង្គការ ផ្សេងៗទៀត ក្នុងនោះរួមមានអង្គការអ្នកជំនួយមេធាវី ក្នុងការផ្តល់សេវាជំនួយផ្នែកច្បាប់ទូទាំងប្រទេស ជាពិសេស នៅតាមតំបន់ជនបទ ដែលជួបវិបត្តិផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច

(ខ) កំណត់យន្តការសារពើពន្ធសម្រាប់បញ្ជូនមូលនិធិដល់ជំនួយផ្នែកច្បាប់ ដូចជា៖

(I) ធ្វើវិភាជន៍ថវិកាយុត្តិធម៌ព្រហ្មទណ្ឌរបស់រដ្ឋជាភាគរយសំរាប់សេវាជំនួយផ្នែកច្បាប់ ដែលសមស្របទៅនឹងសេចក្តីត្រូវការនៃការផ្តល់ជំនួយផ្នែកច្បាប់ប្រកបដោយប្រសិទ្ធភាព។

(II) ប្រើប្រាស់ថវិកាដែលទទួលបានមកវិញពីសកម្មភាពឧក្រិដ្ឋ តាមរយៈការរឹបអូសយក ឬការពិន័យជាប្រាក់ ដើម្បីចំណាយទៅលើជំនួយផ្នែកច្បាប់សម្រាប់ជនរងគ្រោះ។

(គ) កំណត់ និងដាក់ឲ្យដំណើរការនូវគ្រឿងលើកទឹកចិត្ត សម្រាប់មេធាវីចុះធ្វើការនៅតាមតំបន់ជនបទ និង តំបន់ដែលជួបវិបត្តិផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច (ឧទាហរណ៍ៈ ការលើកលែងពន្ធ ឬការកាត់បន្ថយពន្ធ ការកាត់បន្ថយ សំណងទូទាត់ប្រាក់កម្ចីរបស់និស្សិត)។

(ឃ) ធានាឲ្យមានការបែងចែកត្រឹមត្រូវ និងជាសមាមាត្រនូវមូលនិធិរវាងស្ថាប័នអយ្យការ និងទីភ្នាក់ងារជំនួយ ផ្នែកច្បាប់។

៦២. ថវិកាសម្រាប់ជំនួយផ្នែកច្បាប់ត្រូវមានគ្រប់គ្រាន់ សម្រាប់ចំណាយទៅលើសេវាសព្វគ្រប់ ដែលត្រូវផ្តល់ដល់ជន ទាំងឡាយដែលត្រូវបានឃុំខ្លួន ចាប់ខ្លួន ឬត្រូវបានកាត់ឲ្យជាប់ទោសដាក់ពន្ធនាគារ សង្ស័យ ឬត្រូវបានចោទប្រកាន់ ឬ ត្រូវជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ហើយនឹងត្រូវផ្តល់ដល់ជនរងគ្រោះ។ មូលនិធិពិសេសគ្រប់គ្រាន់ត្រូវតែលៃលកទុក សំរាប់ចំណាយទៅលើការការពារក្តី ដូចជាចំណាយលើការថតចម្លងសំណុំរឿង និងឯកសារពាក់ព័ន្ធ និងការប្រមូល ភស្តុតាង ចំណាយពាក់ព័ន្ធនឹងសាក្សីជំនាញ អ្នកជំនាញខាងកោសលវិច័យ និងមន្ត្រីសង្គមកិច្ច ព្រមទាំងចំណាយលើ ការធ្វើដំណើរ។ ការទូទាត់ចំណាយគួរតែត្រូវធ្វើឲ្យបានទាន់ពេលវេលា។

## គោលការណ៍ណែនាំទី១៣៖ ជនជានមនុស្ស

៦៣. ក្នុងករណីសមស្រប រដ្ឋទាំងឡាយ ត្រូវតែជ្រើសរើសបុគ្គលិកឲ្យបានគ្រប់គ្រាន់ និងជាក់លាក់សំរាប់ប្រព័ន្ធជំនួយផ្នែកច្បាប់ទូទាំងប្រទេស ដែលសមស្របនឹងសេចក្តីត្រូវការរបស់ខ្លួន។

៦៤. រដ្ឋទាំងឡាយត្រូវតែធានាថា មន្ត្រីជំនាញ ដែលធ្វើការដើម្បីប្រព័ន្ធជំនួយផ្នែកច្បាប់ថ្នាក់ជាតិ ត្រូវមានគុណវុឌ្ឍិ និងការបណ្តុះបណ្តាលសមស្របសម្រាប់សេវាដែលពួកគេផ្តល់ជូន។

៦៥. ក្នុងករណីមានមេធាវីជំនាញមិនគ្រប់គ្រាន់ ការផ្តល់សេវាជំនួយផ្នែកច្បាប់ក៏អាចរាប់បញ្ចូលផងដែរ នូវអ្នកដែលមិនមែនជាមេធាវី ឬអ្នកជំនួយមេធាវី។ ក្នុងពេលជាមួយគ្នានេះ រដ្ឋទាំងឡាយ គួរតែលើកកម្ពស់កំណើនវិជ្ជាជីវៈច្បាប់ និងបំបាត់ចោលឧបសគ្គផ្នែកហិរញ្ញវត្ថុដល់ការអប់រំផ្នែកច្បាប់។

៦៦. រដ្ឋទាំងឡាយក៏គួរតែលើកទឹកចិត្តផងដែរ ឲ្យមានសិទ្ធិទូលំទូលាយក្នុងការទទួលបានវិជ្ជាជីវៈច្បាប់ ក្នុងនោះរួម មានវិធានការចំណាត់ការជាវិជ្ជមាន ដើម្បីធានាឲ្យមានលទ្ធភាពសម្រាប់ស្ត្រី ជនជាតិភាគតិច និងក្រុមមនុស្សប្រឈម នឹងវិបត្តិផ្នែកសេដ្ឋកិច្ច។

## គោលការណ៍ណែនាំទី១៤៖ អ្នកជំនួយមេធាវី

៦៧. ដោយអនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួន និងក្នុងករណីសមស្រប រដ្ឋទាំងឡាយត្រូវទទួលស្គាល់តួនាទី ដែលត្រូវបានបំពេញដោយអ្នកជំនួយមេធាវី ឬមន្ត្រីដែលផ្តល់សេវាស្រដៀងគ្នានេះ ក្នុងការផ្តល់សេវាជំនួយផ្នែកច្បាប់ ក្នុងករណីលទ្ធភាពទទួលបានមេធាវីមានកម្រិត។

៦៨. សម្រាប់គោលបំណងនេះ រដ្ឋទាំងឡាយ ដោយពិគ្រោះយោបល់ជាមួយនឹងសង្គមស៊ីវិល និងទីភ្នាក់ងារយុត្តិធម៌ និងសមាគមវិជ្ជាជីវៈច្បាប់ ត្រូវតែដាក់ចេញនូវវិធានការដូចតទៅ ដើម្បី៖

(ក) ក្នុងករណីសមស្រប បង្កើតគម្រោងសេវាអ្នកជំនួយមេធាវីទូទាំងប្រទេស ជាមួយនឹងកម្មវិធីបណ្ដុះបណ្ដាលដែលត្រូវធ្វើឲ្យទៅជាស្តង់ដា និងគម្រោងទទួលស្គាល់ជាផ្លូវការ ក្នុងនោះរួមមានការជ្រើសរើសយ៉ាងសម្រិតសម្រាំង និងការត្រួតពិនិត្យវាយតម្លៃពីលក្ខណៈសម្បត្តិសមស្រប។

(ខ) ធានាថាបទដ្ឋានគុណភាពសម្រាប់សេវាអ្នកជំនួយមេធាវីត្រូវបានកំណត់ និងថាអ្នកជំនួយមេធាវី ទទួលបានការបណ្ដុះបណ្ដាលគ្រប់គ្រាន់ និងប្រតិបត្តិការក្រោមការត្រួតពិនិត្យមើលរបស់មេធាវីជំនាញ។

(គ) ធានាឲ្យមានយន្តការពិនិត្យតាមដាន និងវាយតម្លៃដើម្បីធានាគុណភាពនៃសេវា ដែលត្រូវបានផ្តល់ដោយអ្នកជំនួយមេធាវី។

(ឃ) ដោយពិគ្រោះយោបល់ជាមួយនឹងសង្គមស៊ីវិលនិងទីភ្នាក់ងារយុត្តិធម៌ លើកកម្ពស់ការបង្កើតក្រមសីលធម៌ ដែលដាក់ឲ្យភ្ជាប់កាតព្វកិច្ចចំពោះអ្នកជំនួយមេធាវីទាំងអស់ ដែលធ្វើការនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។

(ង) កំណត់ឲ្យបានជាក់លាក់នូវប្រភេទសេវាផ្នែកច្បាប់ ដែលអាចត្រូវផ្តល់ដោយអ្នកជំនួយមេធាវី និងប្រភេទសេវាដែលត្រូវផ្តល់ដោយមេធាវីផ្ទាល់មុខ លើកលែងតែការកំណត់បែបនេះ ស្ថិតនៅក្នុងសមត្ថកិច្ចរបស់តុលាការ ឬគណៈមេធាវី។

(ច) ធានាឲ្យមានលទ្ធភាពសម្រាប់អ្នកជំនួយមេធាវី ដែលត្រូវបានទទួលស្គាល់ជាផ្លូវការ និងដែលត្រូវបានចាត់តាំងឲ្យផ្តល់ជំនួយផ្នែកច្បាប់ដល់អង្គភាពនគរបាល និងពន្ធនាគារ ទីកន្លែងឃុំខ្លួន ឬមណ្ឌលឃុំខ្លួនបណ្តោះអាសន្នផ្សេងៗទៀត។ល។

(ឆ) ដោយអនុលោមតាមច្បាប់ជាតិ និងលិខិតបទដ្ឋានក្រោមច្បាប់ អនុញ្ញាតឲ្យអ្នកជំនួយមេធាវីដែលត្រូវបានទទួលស្គាល់ជាផ្លូវការដោយតុលាការ និងដែលត្រូវបានបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវ ចូលរួមក្នុងដំណើរការនីតិវិធីតាមផ្លូវតុលាការ និងណែនាំដល់ជនជាប់ចោទ នៅពេលដែលមិនមានមេធាវីបំពេញការងារដូច្នេះ។

## *គោលការណ៍ណែនាំទី១៥៖ លិខិតបទដ្ឋានក្រោមច្បាប់ និងការត្រួតពិនិត្យមើលមន្ត្រីជំនួយផ្នែកច្បាប់*

៦៩. ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ទី១២ និងដោយគោរពទៅតាមច្បាប់ជាតិដែលនៅជាធរមាន ដែលធានាឲ្យមានតម្លាភាព និងគណនេយ្យភាព ហើយដោយមានសហប្រតិបត្តិការជាមួយនឹងសមាគមវិជ្ជាជីវៈច្បាប់រដ្ឋទាំងឡាយ ត្រូវ៖

(ក) ធានាថា លក្ខណៈវិនិច្ឆ័យត្រូវបានកំណត់ សម្រាប់ទទួលស្គាល់មន្ត្រីជំនួយផ្នែកច្បាប់ជាផ្លូវការ។

(ខ) ធានាថា មន្ត្រីផ្នែកច្បាប់ត្រូវគោរពតាមក្រមសីលធម៌វិជ្ជាជីវៈដែលអាចអនុវត្តបាន ជាមួយនឹងការដាក់ទណ្ឌកម្មសមស្របចំពោះការប្រព្រឹត្តល្មើសនឹងក្រមនេះ។

(គ) រៀបចំបង្កើតវិធាននានា ដើម្បីធានាថាមន្ត្រីជំនួយផ្នែកច្បាប់ មិនត្រូវបានអនុញ្ញាតឲ្យស្នើសុំបង់ថ្លៃសេវាណាមួយពីអ្នកទទួលផលពីជំនួយផ្នែកច្បាប់ឡើយ វៀរលែងតែ នៅពេលដែលត្រូវបានផ្តល់ការអនុញ្ញាតឲ្យធ្វើដូច្នោះ។

(ឃ) ធានាថាបណ្តឹងពាក់ព័ន្ធនឹងវិន័យប្រឆាំងនឹងមន្ត្រីជំនួយផ្នែកច្បាប់ ត្រូវតែបានពិនិត្យឡើងវិញដោយ ស្ថាប័នទាំងឡាយដែលមិនលំអៀង។

(ង) រៀបចំបង្កើតយន្តការត្រួតពិនិត្យសមស្របនានា សម្រាប់មន្ត្រីជំនួយផ្នែកច្បាប់ ជាពិសេស ក្នុងគោលបំណងបង្ការអំពើពុករលួយ។

## *គោលការណ៍ណែនាំទី១៦៖ ភាពជាដៃគូជាមួយសកលវិទ្យាល័យ និងជាមួយមន្ត្រីផ្តល់សេវាជំនួយផ្នែកច្បាប់ដែលមិនមែនជាមន្ត្រីរដ្ឋ*

៧០. ក្នុងករណីសមស្រប រដ្ឋទាំងឡាយត្រូវចូលរួមក្នុងភាពជាដៃគូជាមួយមន្ត្រីផ្តល់សេវាជំនួយផ្នែកច្បាប់ដែលមិនមែនជាមន្ត្រីរដ្ឋ ក្នុងនោះរួមមានអង្គការមិនមែនរដ្ឋាភិបាល និងមន្ត្រីផ្តល់សេវាផ្សេងៗទៀត។

៧១. ដើម្បីសម្រេចគោលដៅនេះ រដ្ឋទាំងឡាយ គួរតែចាត់វិធានការដូចតទៅ ដោយពិគ្រោះយោបល់ជាមួយនឹងសង្គមស៊ីវិល ទីភ្នាក់ងារយុត្តិធម៌ និងសមាគមវិជ្ជាជីវៈច្បាប់ទាំងឡាយ ដើម្បី៖

(ក) ទទួលស្គាល់នៅក្នុងប្រព័ន្ធច្បាប់របស់ខ្លួន នូវតួនាទីដែលត្រូវបានបំពេញដោយតួអង្គដែលមិនមែនជាតួអង្គរដ្ឋ ក្នុងការផ្តល់សេវាជំនួយផ្នែកច្បាប់ ដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

(ខ) កំណត់ស្តង់ដាគុណភាពសម្រាប់សេវាជំនួយផ្នែកច្បាប់ និងគាំទ្រដល់ការបង្កើតកម្មវិធីបណ្តុះបណ្តាល ដែលត្រូវធ្វើឲ្យទៅជាស្តង់ដា សម្រាប់មន្ត្រីផ្តល់សេវាជំនួយផ្នែកច្បាប់ដែលមិនមែនជាមន្ត្រីរដ្ឋ។

(គ) រៀបចំបង្កើតយន្តការពិនិត្យតាមដាន និងវាយតម្លៃទាំងឡាយ ដើម្បីធានាឲ្យសេវាជំនួយផ្នែកច្បាប់មានគុណភាព ជាពិសេស សេវាដែលត្រូវបានផ្តល់ដោយឥតគិតថ្លៃ។

(ឃ) ធ្វើការជាមួយមន្ត្រីផ្តល់សេវាជំនួយផ្នែកច្បាប់ទាំងអស់ ដើម្បីបង្កើនការផ្សព្វផ្សាយដល់មូលដ្ឋាន គុណភាព និងឥទ្ធិពល និងសម្របសម្រួលសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ នៅគ្រប់តំបន់នៃប្រទេស និងនៅគ្រប់សហគមន៍ ជាពិសេស នៅតំបន់ជនបទ និងតំបន់ប្រឈមវិបត្តិផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច និងនៅក្នុងចំណោមក្រុមអម្បូរជនជាតិភាគតិច។

(ង) ធ្វើឲ្យមានភាពចម្រុះនូវមន្ត្រីផ្តល់សេវាជំនួយផ្នែកច្បាប់ ដោយអនុម័តយុទ្ធវិធីដ៏ទូលំទូលាយមួយ ឧទា. ដោយលើកទឹកចិត្តដល់ការរៀបចំបង្កើតមជ្ឈមណ្ឌលនានា ដើម្បីផ្តល់សេវាជំនួយផ្នែកច្បាប់ដែលមានបុគ្គលិកជាមេធាវី និងអ្នកជំនួយមេធាវី និងដោយចុះកិច្ចព្រមព្រៀងជាមួយនឹងសមាគមមេធាវី និងគណៈមេធាវី ការិយាល័យពិគ្រោះច្បាប់នៅសកលវិទ្យាល័យ និងអង្គការមិនមែនរដ្ឋាភិបាល និងអង្គការផ្សេងៗទៀត ដើម្បីផ្តល់សេវាជំនួយផ្នែកច្បាប់។

៧២. ក្នុងករណីសមស្របរដ្ឋទាំងឡាយ ត្រូវចាត់វិធានការដូចតទៅផងដែរ ដើម្បី៖

(ក) លើកទឹកចិត្ត និងគាំទ្រដល់ការរៀបចំបង្កើតការិយាល័យជំនួយផ្នែកច្បាប់ នៅក្នុងនាយកដ្ឋានច្បាប់នៃសកលវិទ្យាល័យ ដើម្បីលើកកម្ពស់កម្មវិធីច្បាប់សម្រាប់ផលប្រយោជន៍សាធារណៈ និងកម្មវិធីណែនាំផ្នែកច្បាប់ក្នុងចំណោមសមាជិកមហាវិទ្យាល័យ និងស្ថាប័ននិស្សិត ក្នុងនោះរួមមានកម្មវិធីសិក្សាដែលត្រូវបានទទួលស្គាល់ជាផ្លូវការរបស់សកលវិទ្យាល័យ។

(ខ) លើកទឹកចិត្ត និងផ្តល់គ្រឿងលើកទឹកចិត្តដល់និស្សិតផ្នែកច្បាប់ដើម្បីចូលរួមក្នុងការិយាល័យជំនួយផ្នែកច្បាប់ ឬគម្រោងសហគមន៍ជំនួយផ្នែកច្បាប់ផ្សេងៗទៀតជាផ្នែកមួយនៃកម្មវិធីសិក្សា ឬការអភិវឌ្ឍខាងវិជ្ជាជីវៈច្បាប់ ក្រោមការត្រួតពិនិត្យមើលយ៉ាងសមស្រប និងដោយអនុលោមតាមច្បាប់ ឬទម្លាប់អនុវត្តថ្នាក់ជាតិ។

(គ) ក្នុងករណីមិនទាន់មាន បង្កើតវិធានកម្មសិក្សារបស់និស្សិត ដែលអនុញ្ញាតឲ្យនិស្សិតធ្វើកម្មសិក្សានៅតាមតុលាការ ក្រោមការត្រួតពិនិត្យមើលរបស់មេធាវីជំនាញ ឬបុគ្គលិកមហាវិទ្យាល័យ ឲ្យតែវិធានបែបនេះត្រូវបានបង្កើតឡើង ដោយពិគ្រោះយោបល់ជាមួយនឹង ហើយនឹងទទួលយកដោយតុលាការមានសមត្ថកិច្ច ឬបណ្តាស្ថាប័នដែលបញ្ញត្តនូវការធ្វើកម្មសិក្សាច្បាប់ នៅចំពោះមុខតុលាការ។

(ឃ) បង្កើតវិធានសម្រាប់អនុញ្ញាតឲ្យនិស្សិតផ្នែកច្បាប់ ធ្វើកម្មសិក្សានៅតាមតុលាការក្រោមការត្រួតពិនិត្យមើលរបស់មេធាវីជំនាញ នៅក្នុងយុត្តាធិការដែលតម្រូវឲ្យពួកគេហាត់ធ្វើការផ្នែកច្បាប់។

## *គោលការណ៍ណែនាំទី១៧៖ ការស្រាវជ្រាវ និងទិន្នន័យ*

៧៣. រដ្ឋទាំងឡាយត្រូវធានាថាយន្តការតាមដាន ពិនិត្យឃ្លាំមើល និងវាយតម្លៃជំនួយផ្នែកច្បាប់ ត្រូវរៀបចំបង្កើតឡើង និងត្រូវបន្តព្យាយាមធ្វើឲ្យប្រសើរឡើងនូវការផ្ដល់ជំនួយផ្នែកច្បាប់នេះ។

៧៤. សម្រាប់គោលបំណងនេះ រដ្ឋទាំងឡាយ អាចដាក់ចេញនូវវិធានការដូចតទៅ ដើម្បី៖

(ក) ធ្វើការស្រាវជ្រាវជាទៀងទាត់ និងប្រមូលទិន្នន័យដែលត្រូវបែងចែកទៅតាមភេទ អាយុ ស្ថានភាព សេដ្ឋកិច្ច-សង្គមកិច្ច និងអ្នកទទួលជំនួយផ្នែកច្បាប់តាមភូមិសាស្ត្រ និងផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវបែបនេះ។

(ខ) ចែករំលែកទម្លាប់អនុវត្តន៍ត្រឹមត្រូវក្នុងការផ្ដល់ជំនួយផ្នែកច្បាប់។

(គ) ពិនិត្យតាមដានការផ្ដល់ប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាពនូវជំនួយផ្នែកច្បាប់ ដោយអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

(ឃ) ផ្ដល់ការបណ្ដុះបណ្ដាលជាលក្ខណៈវប្បធម៌ចម្រុះ សមស្របតាមវប្បធម៌ ផ្ដោតលើយេនឌ័រ និងសមស្របតាមអាយុដល់មន្ត្រីជំនួយផ្នែកច្បាប់។

(ង) ធ្វើឲ្យប្រសើរឡើងនូវការទំនាក់ទំនង ការសម្របសម្រួល និងសហប្រតិបត្តិការរវាងទីភ្នាក់ងារយុត្តិធម៌ ទាំងអស់ ជាពិសេសនៅថ្នាក់មូលដ្ឋាន ដើម្បីកំណត់អំពីបញ្ហាទាំងឡាយនៅមូលដ្ឋាន និងដើម្បីឲ្យមានការព្រមព្រៀង លើដំណោះស្រាយ ក្នុងការធ្វើឲ្យប្រសើរឡើងនូវការផ្ដល់ជំនួយផ្នែកច្បាប់។

## *គោលការណ៍ណែនាំទី១៨៖ ជំនួយបច្ចេកទេស*

៧៥. ជំនួយបច្ចេកទេសផ្អែកលើសេចក្ដីត្រូវការ និងអាទិភាពដែលបានកំណត់ដោយរដ្ឋស្នើសុំទាំងឡាយ គួរតែត្រូវបានផ្ដល់ពីអង្គការអន្តររដ្ឋាភិបាលពាក់ព័ន្ធ ដូចជា អង្គការសហប្រជាជាតិ ម្ចាស់ជំនួយទ្វេភាគី និងអង្គការមិនមែនរដ្ឋាភិបាលដែលមានសមត្ថកិច្ច ក៏ដូចជា រដ្ឋទាំងឡាយនៅក្នុងក្របខ័ណ្ឌសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ក្នុងគោលបំណងកសាង និងលើកកម្ពស់សមត្ថភាព និងស្ថាប័នជាតិនានា សម្រាប់បង្កើត និងអនុវត្តប្រព័ន្ធជំនួយផ្នែកច្បាប់ និងកំណែទម្រង់យុត្តិធម៌ព្រហ្មទណ្ឌ តាមករណីសមស្រប។

☞☞☞@☜☜☜